**អង្គការសហប្រជាជាតិ** E

**ក្រុមប្រឹក្សាសេដ្ឋកិច្ច**
**និងសង្គមកិច្ច**

ការចែកចាយទូទៅ
E/CN.4/2003/114
ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២
អត្ថបទដើម: អង់គ្លេស

គណៈកម្មការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី ៥៩
ចំណុចទី ១៩ នៃរបៀបវារៈបណ្តោះអាសន្ន

# សេវាទីប្រឹក្សា និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យសិទ្ធិមនុស្ស

## ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

របាយការណ៍របស់លោក ប៉េតឺរ លយប្រែកតឺ តំណាងពិសេសរបស់លោកអគ្គលេខាធិការ
ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដាក់ជូនដោយអនុលោមទៅតាមសេចក្តីសំរេចចិត្ត
របស់គណៈកម្មការលេខ ២០០២/៨៩

# សេចក្តីសង្ខេបខាងការប្រតិបត្តិ

ប្រទេសកម្ពុជាកំពុងរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី ៣ របស់ខ្លួន ចាប់តាំងពីការចុះហត្ថលេខាលើ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១ មក។ ការបោះឆ្នោតសភានាពេលខាងមុខនេះ គឺជាការកំណត់សំខាន់មួយ ដោយប្រទេសកម្ពុជាខិតខំដើម្បីចាក់ឫសឱ្យបានជ្រៅក្នុងលទ្ធិប្រជាធិបតេយ្យពហុបក្ស។ ដើម្បីធានាថាសិទ្ធិមនុស្សត្រូវបានធានាដោយពេញលេញ កិច្ចខិតខំដ៏ហ្មត់ចត់ក៏ត្រូវតែចាត់ឱ្យមានឡើង ដើម្បីអភិវឌ្ឍន៍បន្ថែមទៀតនូវក្របខ័ណ្ឌច្បាប់ ពង្រឹងប្រព័ន្ធតុលាការ បញ្ចប់បញ្ហានិទ័ណ្ឌភាព ប្រយុទ្ធនឹងអំពើពុករលួយ និងជាទូទៅចាត់ឱ្យមានឡើង និងអនុវត្តនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលការពារ និងធានាសិទ្ធិមនុស្សដល់ប្រជាពលរដ្ឋកម្ពុជា ដូចដែលបានធានានៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ច្បាប់នានារបស់ប្រទេសកម្ពុជា និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលប្រទេសកម្ពុជាបានចូលជាភាគី។

ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ស្ថិតនៅជាបញ្ហាដែលពិបាកយល់បំផុតនៃកិច្ចខិតខំកែទម្រង់របស់ប្រទេសកម្ពុជា ហើយដូចនេះ វាបន្តស្ថិតនៅជាការកង្វល់របស់តំណាងពិសេស។ អាស្រ័យដោយភាគីជាមជ្ឈមណ្ឌលនៃប្រព័ន្ធតុលាការមួយឯករាជ្យ មានសមត្ថភាព និងប្រសិទ្ធភាពសំរាប់ធានាសិទ្ធិមនុស្សតាមនីតិរដ្ឋនោះ កិច្ចខិតខំនេះមានសារសំខាន់ណាស់ និងជាបេះដូងនៃបញ្ហាជាគន្លឹះជាច្រើន។ ការលំបាកប្រឈមមុខទៅនឹងបញ្ហានេះ គ្របដណ្តប់បញ្ហាដ៏ទូលំទូលាយក្នុងយន្តកម្ម តុលាការ និងការតាក់តែងច្បាប់ ដែលបានលើកឡើងនៅក្នុងរបាយការណ៍លើកមុនៗ។ ប្រព័ន្ធតុលាការបន្តញាំញីដោយអំពើពុករលួយ និងការខ្វះឯករាជភាពនិងភាពមិនលំអៀង។ ការខ្វះខាតដ៏ធ្ងន់ធរនូវមេធាវីសំរាប់ប្រជាពលរដ្ឋ១២លាននាក់ ដោយមេធាវីដែលត្រូវទទួលស្គាល់ស្ទើរតែទាំងអស់ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ មានន័យថាប្រជាពលរដ្ឋភាគច្រើន ដែលចូលខ្លួនចំពោះមុខតុលាការ ពុំមានអ្នកតំណាងរបស់ខ្លួនទេ។ បញ្ហានិទ័ណ្ឌភាពបន្តប៉ះពាល់ដល់លទ្ធភាពដែលប្រជាពលរដ្ឋកម្ពុជា ក្នុងការទទួលបាននូវភាពយុត្តិធម៌។ បុគ្គលមានអំណាចនិងអាជ្ញាធររដ្ឋ ជាពិសេសអ្នកអនុវត្តច្បាប់ និងកម្លាំងប្រដាប់អាវុធ ត្រូវបានចាប់ឱ្យទទួលខុសត្រូវតិចតួចណាស់ ចំពោះអំពើឧក្រិដ្ឋដែលពួកគេ បានប្រព្រឹត្ត។

វិធានការថ្មីៗនេះ គឺជាជំហានឆ្ពោះទៅកាន់ទិសត្រឹមត្រូវហើយ ប៉ុន្តែនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ឧទាហរណ៍ សាលាភូមិន្ទថ្មីសំរាប់ហ្វឹកហ្វឺនចៅក្រម និងព្រះរាជអាជ្ញា អាចមានឥទ្ធិពលគ្រប់

គ្រាន់សំរាប់គុណភាពនៃការគ្រប់គ្រងផ្នែកយុត្តិធម៌ ហើយឥទ្ធិពលរបស់វាសង្ឃឹមថានឹងអាចត្រូវបានដឹងនៅក្នុងរយៈពេលយូរអង្វែង។ ការដំឡើងដ៏គួរឱ្យកត់សំគាល់ នូវប្រាក់ខែរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងខែវិច្ឆិកា អាចជួយទប់អំពើពុករលួយ បើសិនជាគួបផ្សំទៅជាមួយនិងការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ដែលទន្ទឹងរង់ចាំជាយូរមកហើយ និងវិធានការយ៉ាងសកម្មពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាអង្គការមួយត្រូវបានប្រគល់នាទីឱ្យធានាឯករាជភាពរបស់តុលាការ និងរក្សាវិន័យក្នុងចំណោមចៅក្រម និងព្រះរាជអាជ្ញា។ ប៉ុន្តែអង្គការនេះតម្រូវឱ្យធ្វើការ កែទម្រង់រចនាសម្ព័ន្ធជាមូលដ្ឋាន ហើយខ្លួនឯងក៏ត្រូវឯករាជ្យផងដែរ បើសិនជាចង់បំពេញភារកិច្ចនេះរបស់ខ្លួន។ ដូចគ្នានេះដែរ មាត្រា ១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយត្រូវធ្វើវិសោធនកម្ម ដើម្បីបំបែកខ្លួនសមាជិកក្រុមប្រឹក្សាចៅក្រម នឹងព្រះរាជអាជ្ញាឱ្យដាច់ចេញពីឥទ្ធិពលនយោបាយ។ ការកំណត់រយៈពេលសំរាប់អនុវត្តន៏មួយចំនួនដូចដែលព្រមព្រៀងកាលពីពេលប្រជុំក្រុមប្រឹក្សាយោបល់នៃប្រទេសផ្តល់ជំនួយ កាលពីខែមិថុនា ឆ្នាំ ២00២ គួរបានដាក់បញ្ចូល និងធ្វើឱ្យទៅជាកម្មវត្ថុនៃការចរចាឱ្យបានហ្មឹងមាត់ និងជាបន្តជាប់លាប់ រវាងប្រទេសផ្តល់ជំនួយ និងរដ្ឋាភិបាល។

ចំពោះការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី ៣ នៅកម្ពុជា ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសកាលពីឆ្នាំ ១៩៩១មក ដែលនឹងប្រព្រឹត្តទៅនៅក្នុងខែកក្កដា ឆ្នាំ ២00៣ តំណាងពិសេសមានកង្វល់អំពីបញ្ហាជាច្រើន ដែលបានកើតមានយូរមកហើយផងដែរ។ រាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលទើបជ្រើសតាំងថ្មី ត្រូវខិតខំឱ្យបានខ្លាំងក្លាដើម្បីធានាឱ្យគ្រប់គណបក្សនយោបាយទាំងអស់ អាចមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពិតមានរបស់រដ្ឋដោយសមស្រប ហើយក៏ត្រូវជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ពតិមានមិនមែនជារបស់រដ្ឋផងដែរ ជាពិសេសប្រព័ន្ធផ្សព្វផ្សាយពិតមានអេឡិចត្រូនីក។ ក្នុងការប្រឈមមុខនឹងការលួចបន្លំសន្លឹកឆ្នោត ការទិញសន្លឹកឆ្នោត ការប្រើ និងការអុជអាលឱ្យមានអំពើហឹង្សា និងបញ្ហាដទៃទៀត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ត្រូវប្រើប្រាស់អំណាចដ៏ធំធេងរបស់ខ្លួន ដើម្បីធ្វើការផាកដាក់ពិន័យ និងការដាក់ទណ្ឌកម្មផ្សេងទៀត។ មន្ត្រីពង្រឹងការអនុវត្តច្បាប់ បានបង្ហាញអំពីការប្តេជ្ញាចិត្តចូលពាក់ព័ន្ធរបស់ខ្លួន ដើម្បីធ្វើការស៊ើបអង្កេតលើករណី ឃាតកម្មទាក់ទិននឹងការបោះឆ្នោតកាលពីពេលថ្មីៗនេះ ក៏ប៉ុន្តែកិច្ចដំណើរការរបស់តុលាការក្នុងការនាំខ្លួន ជនល្មើសទៅរកយុត្តិធម៌នៅតែមានគុណវិបត្តិដដែល។

រាជរដ្ឋាភិបាលបានបន្តនយោបាយផ្តល់ដី ព្រៃឈើ និងផ្តល់សម្បទានប្រភេទដទៃទៀតដោយទ្រង់ទ្រាយធំដល់ក្រុមហ៊ុនឯកជន។ តាមការពិសោធរហូតមកទល់ពេលនេះ បានបង្ហាញឱ្យឃើញថាការនេះគឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរដល់សុខុមាលភាពនៃពួកអ្នករស់នៅលើទឹកដីទាំងនោះ ហើយក៏បានរួមចំណែកដល់បញ្ហាសិទ្ធិក្នុងការទទួលបានដីធ្លីចំពោះប្រជាពលរដ្ឋជាទូទៅផងដែរ។ តំណាងពិសេសសូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមឱ្យពិនិត្យឡើងវិញនូវកិច្ចសន្យាសម្បទានដីកសិកម្មទាំងអស់ និងអំពីការអនុវត្តន៍កិច្ចសន្យាទាំងនេះ ព្រមទាំងពិនិត្យពិចារណាក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួនធ្វើការដកហូតយកមកវិញ ក្នុងករណីបើមិនគោរពតាមបទបញ្ញត្តិនៃច្បាប់កម្ពុជា និងលក្ខខណ្ឌកំណត់ក្នុងកិច្ចសន្យា។ ការរំជើបរំជួលនាពេលថ្មីៗនេះ អំពីការផ្តល់ពេលមិនគ្រប់គ្រាន់ដល់សាធារណៈជន ដើម្បីធ្វើការសិក្សា និងផ្តល់មតិលើគំរោងផែនការផ្តល់ឱ្យសម្បទាន បន្តគ្រប់គ្រងព្រៃឈើក្នុងរយៈពេល ២៥ ឆ្នាំតទៅទៀត ឆ្លុះបញ្ចាំងឱ្យឃើញពីការមិនយកចិត្តទុកដាក់ដល់សហគមន៏ ដែលត្រូវទទួលផលប៉ះពាល់។

ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋកម្ពុជាដែលត្រូវផ្លាស់ប្តូរទីកន្លែង ស្ថិតនៅជាបញ្ហានៃកង្វល់ដដែល។ ទីកន្លែងតាំងទីលំនៅថ្មី ដូចជាអន្លង់ក្ងាន ត្រូវបានយកទៅដាក់បន្ទាប់ពីភ្លើងឆេះបំផ្លាញតំបន់ក្រីក្រនៅបាសាក់ និងដើមចាន់ នៃទីក្រុងភ្នំពេញកាលពីឆ្នាំ ២០០១។ ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ ក៏បណ្តាលឱ្យមានការផ្លាស់ប្តូរទីកន្លែងផងដែរ។ សហគមន៏អន់ខ្សោយទាំងនេះ ត្រូវបានបង្ខំឱ្យទៅរស់នៅលើតំបន់ទាំងនេះ ដោយប្រឈមមុខនឹងការព្រួយបារម្ភខាងសន្តិសុខ និងការខ្វះខាតទឹក អនាម័យ សុខភាព និងការអប់រំ។ ឱកាសរកទទួលទានមានកំរិត ទាមទារឱ្យអ្នកតាំងទីលំនៅថ្មីធ្វើដំណើរដ៏ឆ្ងាយជារៀងរាល់ថ្ងៃទៅធ្វើការ។ នៅក្នុងខែសីហា ឆ្នាំ ២០០១ អង្គការក្រៅរដ្ឋាភិបាលជាច្រើន បានរៀនចំចងក្រងគោលការណ៏ការណែនាំស្តីពីការតាំងលំនៅថ្មីមួយចំនួន ដោយឱ្យមានការចូលរួមពីខាងរាជធានីភ្នំពេញ ដែលតំណាងពិសេសសូមសរសើរចំពោះអាជ្ញាធរ ដោយបានផ្តល់មូលដ្ឋានសំរាប់គោលការណ៏ដ៏ត្រឹមត្រូវ ដើម្បីដោះស្រាយបញ្ហាដ៏លំបាកទាំងនេះ។

ទាំងអតីតឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងតំណាងពិសេស បានគូសបញ្ជាក់អំពីការជួញដូរមនុស្ស ថាជាបញ្ហាដែលជាកង្វល់ដ៏ធំ។ ការជួញដូរនេះបានកើតមានឡើងទាំងនៅក្នុងប្រទេសផងសំខាន់ពីតំបន់ជនបទមកកាន់មជ្ឈមណ្ឌលទីក្រុង និងទាំងមកពីឬទៅកាន់ប្រទេសជិតខាង។ អ្នកទទួលរងនូវផលប៉ះពាល់ជាសំខាន់ គឺស្ត្រី និងកុមារ។ លទ្ធភាពដែលអាចធ្វើឱ្យមានការរីកចំរើន ក្នុងការប្រយុទ្ធប្រឆាំងអ្នកដែលប្រព្រឹត្តជំនួញនេះ នឹងពុំមានសង្ឃឹមបានឡើយ លើកលែងតែការប្រព្រឹត្តអំពើពុករលួយ

និងការសុខចិត្តធ្វើតាមជាមូលដ្ឋានមួយចំនួនត្រូវបានកែប្រែ ហើយបញ្ហានៃភាពក្រីក្ររកទីបំផុតគ្មាននៅតាមតំបន់ជនបទ ត្រូវបានដោះស្រាយ។ ពួកអ្នកទទួលខុសត្រូវចំពោះការជួញដូរមនុស្ស ដែលត្រូវចោទប្រកាន់ និងបញ្ជូនទៅតុលាការគឺមានចំនួនតិចតួចស្ដួចស្ដើងណាស់ ហើយជាធម្មតាច្រើនធ្វើតែចំពោះអ្នកប្រព្រឹត្តកំហុសនៅថ្នាក់ទាបបំផុតនៃបណ្ដាញឧក្រិដ្ឋកម្មប៉ុណ្ណោះ។

ស្ថានភាពពន្ធនាគារកម្ពុជា ត្រូវបានលើកឡើងនៅក្នុងឯកសារព្រាងរបស់តំណាងពិសេស កាលពីខែវិច្ឆិកា ឆ្នាំ ២០០២ ក្រោមចំណងជើងថា "ឆ្ពោះទៅរកនយោបាយពន្ធនាគារដែលប្រកបដោយមនុស្សធម៌មួយសំរាប់ប្រទេសកម្ពុជា" ដែលការកត់សំគាល់ពីចំណុចចាប់ផ្ដើមមួយ នៃការសន្ទនាគ្នាជាមួយអាជ្ញាធរពន្ធនាគារ។ ទសវត្សរ៍កន្លងមក ចំនួនអ្នកទោសនៅក្នុងពន្ធនាគារបានកើនឡើងជិត៣ដង។ សព្វថ្ងៃ ពន្ធនាគារកម្ពុជាជាច្រើនដាក់មនុស្សលើសចំណុះ ហើយស្ថានភាពនៃពន្ធនាគារខ្លះ មានភាពយ៉ាប់យ៉ឺនខ្លាំងណាស់ ដោយអ្នកទោសខ្វះអាហារ និងទឹកស្អាតមិនគ្រប់គ្រាន់។ ដោយសារការយកការផ្ដន្ទាទោសដាក់ពន្ធនាគារ ធ្វើជាទម្លាប់ធម្មតា ក្នុងការផ្ដន្ទាទោសចំពោះបទព្រហ្មទណ្ឌភាគច្រើន ទោះមានលក្ខណៈស្រាលក៏ដោយ ឧក្រិដ្ឋក៏រិតស្រាលក៏ដោយ ការកើនឡើងយ៉ាងលឿននៃចំនួនអ្នកទោសនៅក្នុងពន្ធនាគារអាចដោះស្រាយ បានដោយការដាក់បញ្ចូលប្រពន្ធការផ្ដន្ទាទោសក្រៅដាក់ពន្ធនាគារជាជំនួសវិញ។ បញ្ហាផ្សេងទៀត ដែលកំពុងពិភាក្សាជាមួយអាជ្ញាធរ រួមមានការកែលំបែបបទក្នុងការអនុញ្ញាតឱ្យចូលជួបអ្នកទោស ការផ្ដល់ការដឹកជញ្ជូនដើម្បីឱ្យអ្នកជាប់ឃុំទៅចូលរួមការកាត់ក្ដីរបស់ខ្លួន និងដោះស្រាយលើបញ្ហាការឃុំខ្លួនបណ្ដោះ អាសន្នហួសរយៈពេលកំណត់។

តាមរបាយការណ៍ជាច្រើនបានឱ្យដឹងថា ជនជាតិភាគតិចនៅតំបន់ភ្នំចំនួនជាច្រើនដែលស្វែងរកជម្រក បានលាក់ខ្លួននៅតាមព្រំដែនប្រទេសទាំងសងខាង ដែលពួកអ្នកស្វែងរកសិទ្ធិជ្រកកោនទាំងនេះត្រូវបានបង្ខំឱ្យត្រឡប់ទៅកាន់ប្រទេសវៀតណាមវិញ ហើយដែលអ្នកដែលបានជួយពួកគេ ត្រូវបានទទួលគំរាមកំហែងទាំងពីសំណាក់អាជ្ញាធរវៀតណាម និងអាជ្ញាធរកម្ពុជា។ ដើម្បីដោះស្រាយកង្វល់ទាំងនេះ រដ្ឋាភិបាលត្រូវអនុវត្តឱ្យបានស្របតាមកាតព្វកិច្ចរបស់ខ្លួន តាមអនុសញ្ញាស្ដីពីឋានៈនៃជនភៀសខ្លួន ដោយយផ្ដល់ការអនុញ្ញាតឱ្យឧត្ដមស្នងការខាងជនភៀសខ្លួន អាចចេញចូលបានដោយសេរីទៅកាន់តំបន់ព្រំដែន ហើយដើម្បីឱ្យពួកគេពិនិត្យដោយមិនលំអៀងនូវពាក្យសុំទាមទារ របស់ពួកស្វែងរកសិទ្ធិជ្រកកោន។

ប្រទេសកម្ពុជានៅតែប្រឈមមុខនឹងការពន្យារពេល និងឧបសគ្គជាច្រើន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើរបាយការណ៍ជូន អ.ស.ប. ស្តីពីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា។ កិច្ចដំណើរការធ្វើរបាយការណ៍ និងអនុសាសន៍របស់អង្គការអនុសញ្ញាត្រូវផ្តល់អាទិភាពឱ្យបានខ្លាំងជាងនេះបន្ថែមទៀត ហើយត្រូវចាត់ទុកជាឱកាសសំរាប់ជួយប្រទេសកម្ពុជា ក្នុងការដាក់បញ្ចូលបទបញ្ញត្តិនៃសន្ធិសញ្ញាទាំងនេះទៅក្នុងច្បាប់ និងការអនុវត្តរបស់ខ្លួន។ តំណាងពិសេស សូមសំដែងការស្ងើចសរសើរដល់របាយការណ៍ស្របពេលគ្នាកាលពីពេលថ្មីៗនេះ រៀបចំដោយគណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលសំរាប់តាមដាន ត្រួតពិនិត្យលើការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលឆ្លុះបញ្ចាំងយ៉ាងល្អិតល្អន់ពីស្ថានភាពជាក់ស្តែង ព្រមទាំងផ្តល់អនុសាសន៍ផ្សេងៗដែលជាជំនួយ ដែលលោកសង្ឃឹមថានឹងត្រូវបានយកចិត្តទុកដាក់ដោយពេញលេញ។

លោកតំណាងពិសេសបានធ្វើសេចក្តីសរុបយោបល់ ក្នុងរបាយការណ៍របស់លោក ដែលមានសេចក្តីសន្និដ្ឋាន និងអនុសាសន៍មួយចំនួន។

# មាតិកា


| | | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|---|
| សេចក្តីសង្ខេបខាងការប្រតិបត្តិ | | | ២ |
| សេចក្តីផ្តើម | | ១-២ | ៩ |
| I. | បេសកកម្មលើកទី ៧ របស់តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា | ៣-១០ | ៩ |
| II. | ការវិវត្តន៍ជាចំបង ៧ និងបញ្ហាសិទ្ធិមនុស្សដែលគួរឱ្យព្រួយបារម្ភ | ១១ | ១២ |
| | ក- ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | ១១-២៣ | ១២ |
| | ខ- បញ្ហានិទ័នណ្ឌភាព | ២៤-២៩ | ១៦ |
| | គ- ពន្ធនាគារ | ៣០-៤០ | ១៨ |
| | ឃ- ការបោះឆ្នោត | ៤១-៤៨ | ២១ |
| | ង- បញ្ហាដីធ្លី និងព្រៃឈើ | ៤៩-៥៩ | ២៣ |
| | ច- បញ្ហាលំនៅដ្ឋាន | ៦០-៦២ | ២៧ |
| | ឆ- ការជួញដូរមនុស្ស | ៦៣-៦៩ | ២៨ |
| | ឈ- អ្នកស្វែងរកសិទ្ធិជ្រកកោន | ៧០-៧២ | ៣០ |
| | ញ- កាតព្វកិច្ចធ្វើរបាយការណ៍ | ៧៣-៧៤ | ៣១ |
| III. | សេចក្តីសន្និដ្ឋាន និងអនុសាសន៍ | ៧៥-៩៨ | ៣២ |
| | ក- ការកែទម្រង់ប្រព័ន្ធតុលាការ | ៧៧-៨២ | ៣៣ |
| | ខ- ការសម្លាប់ដោយហ្វូងមនុស្ស | ៨៣ | ៣៤ |
| | គ- ពន្ធនាគារ | ៨៤-៨៧ | ៣៤ |
| | ឃ- ការបោះឆ្នោត | ៨៨-៨៩ | ៣៤ |

| | | |
|---|---|---|
| ង- បញ្ហាដីធ្លី និងព្រៃឈើ | ៩០-៩២ | ៣៥ |
| ច- តំបន់តាំងទីលំនៅថ្មី | ៩៣ | ៣៥ |
| ឆ- ការជួញដូរមនុស្ស | ៩៤-៩៥ | ៣៦ |
| ជ- អ្នកស្វែងរកសិទ្ធិជ្រកកោន | ៩៦-៩៧ | ៣៦ |
| ឈ- កាតព្វកិច្ចធ្វើរបាយការណ៍ | ៩៨ | ៣៦ |

# សេចក្តីផ្តើម

១-	របាយការណ៍នេះត្រូវបានដាក់ជូនអនុលោមតាមសេចក្តីសំរេចចិត្តលេខ ២០០២/៨៩/២ របស់គណៈកម្មការសិទ្ធិមនុស្ស។ នេះជារបាយការណ៍ទី៣របស់តំណាងពិសេសជូនគណៈកម្មការសិទ្ធិមនុស្ស។

២-	របាយការណ៍នេះធ្វើឡើងដោយផ្អែកតាមរបាយការណ៍លើកមុនៗ របស់តំណាងពិសេសជូនគណៈកម្មការសិទ្ធិមនុស្ស និងមហាសន្និបាត។ ជាទូទៅតំណាងពិសេសនឹងខិតខំជៀសវាងមិននិយាយាស្រំដែលនូវអ្វីដែលលោកបានលើកឡើងនៅក្នុងរបាយការណ៍លើកមុនៗ។ កិច្ចដំណើរការ និងវិធីសាស្រ្តរបស់លោក ស្ថិតនៅដដែល ដូចបានរៀបរាប់នៅក្នុងរបាយការណ៍លើកមុនៗដែរ។

## I- បេសកកម្មលើកទី ៧ របស់តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (ពីថ្ងៃទី ១២ ដល់ ១៩ ខែវិច្ឆិកា ឆ្នាំ ២០០២)

៣-	សេចក្តីត្រូវការជាបន្ទាន់សំរាប់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្ថានភាពពន្ធនាគារ បញ្ហាដីធ្លីនិងលំនៅដ្ឋាន ការរៀបចំការបោះឆ្នោតទូទៅឆ្នាំ ២០០៣ និងបញ្ហាជួញដូរមនុស្ស គឺជាបញ្ហាដែលតំណាងពិសេសផ្តោតការយកចិត្តទុកដាក់ក្នុងពេលមកបំពេញបេសកកម្មលើកទី៧ នៅប្រទេសកម្ពុជា។ តំណាងពិសេសបានជួបប្រជុំជាមួយព្រះមហាក្សត្រព្រះបាទសម្តេច ព្រះនរោត្តម សីហនុ សម្តេចនាយករដ្ឋមន្រ្តី ហ៊ុន សែន អភិបាលរាជធានីភ្នំពេញ ជា សុផារ៉ា ទីប្រឹក្សាសម្តេចនាយករដ្ឋមន្រ្តី ឱម យ៉ិនទៀង រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ នីវ ស៊ីថុង និង ប្រធានរដ្ឋសភា ព្រះអង្គម្ចាស់រណឫទ្ធិ។ តំណាងពិសេសបានជួបជាមួយ សម រង្ស៊ី គ.ជ.ប. ថ្មី ក្រុមប្រឹក្សាសំរាប់ការកែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ និងគណៈមេធាវី។ លោកក៏បានប្រឹក្សាយោបល់ជាមួយតំណាងអង្គការសង្គមស៊ីវិល ប្រទេសផ្តល់ជំនួយ សហគមន៍អង្គការសហប្រជាជាតិ និងសហគមន៍អ្នកការទូត និងបានអញ្ជើញទៅបំពេញទស្សនៈកិច្ចនៅខេត្តកំពង់ស្ពឺ ដើម្បីយល់ដឹងដោយខ្លួនលោកផ្ទាល់អំពីបញ្ហាទាក់ទិននឹងដីសម្បទាន និងផលប៉ះពាល់ចំពោះប្រជាពលរដ្ឋ។

៤-	ការពុះពារជំនះដ៏សំខាន់ និងពិបាកក្នុងការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានលើកឡើងនៅក្នុងកិច្ចប្រជុំជាច្រើនជាមួយមន្រ្តីរដ្ឋាភិបាល និងក្រុមពាក់ព័ន្ធនានា។ សម្តេចនាយករដ្ឋមន្រ្តី នៅក្នុងកិច្ចប្រជុំជាមួយតំណាងពិសេស បានថ្លែងនៅក្នុងកិច្ចខិតខំជាចំបងក្នុងការកែទម្រង់នេះថា ជាវិស័យដែលយឺតបំផុត

ដើម្បីធ្វើការផ្លាស់ប្តូរ។ លោកសង្ឃឹមថាការដំឡើងប្រាក់ខែមុខជានឹងជួយដល់ការកែទម្រង់នេះ ប៉ុន្តែវិធានការខាងវិន័យដ៏តឹងរឹង ក៏ត្រូវការចាំបាច់សំរាប់ប្រឆាំងចំពោះចៅក្រម ដែលបានរកឃើញថា មានកំហុសក្នុងការប្រព្រឹត្តមិនត្រឹមត្រូវ។

៥- ស្ថានភាពពន្ធនាគារកម្ពុជា ត្រូវបានលើកឡើងក្នុងការព្រាងឯកសារពិភាក្សាស្តីពីពន្ធនាគារដែលកត់សំគាល់ពីការចាប់ផ្តើមនៃការចរចារជាមួយអាជ្ញាធរ ដើម្បីធ្វើឱ្យគោលការណ៍ពន្ធនាគារកាន់មានមនុស្សធម៌ថែមទៀត។ តំណាងពិសេសបានធ្វើជាប្រធានសិក្ខាសាលាមួយស្តីពីការកែទម្រង់ពន្ធនាគារដែលនៅពេលនោះមានការចូលរួមពីសំណាក់តំណាងអាជ្ញាធរពន្ធនាគារ និងអង្គការក្រៅរដ្ឋាភិបាលធ្វើការពាក់ព័ន្ធនឹងវិស័យពន្ធនាគារ។

៦- តំណាងពិសេសបានចាប់ផ្តើមស្រាវជ្រាវឱ្យបានកាន់តែជ្រៅលើបញ្ហាដីធ្លី និងបញ្ហាព្រៃឈើពីព្រោះបញ្ហាទាំងពីរនេះ មានផលប៉ះពាល់ចំពោះសុខុមាលភាព និងសិទ្ធិជាមូលដ្ឋាន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមួយភាគធំ។ តំណាងពិសេស បានលើកឡើងពីកង្វល់ខ្លះរបស់លោកជូនសម្តេចនាយករដ្ឋមន្ត្រី និងត្រូវបានទទួលការលើកទឹកចិត្ត ពីសម្តេចនាយករដ្ឋមន្ត្រី ដោយសម្តេចហាក់ដូចជាបានជ្រាបនិងយកចិត្តទុកដាក់ចំពោះបញ្ហានេះដែរ។

៧- ចំពោះការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រក្នុងខែកក្កដា ឆ្នាំ ២០០៣ ខាងមុខនេះ តំណាងពិសេសបានលើកឡើងយ៉ាងទូលំទូលាយពីបញ្ហានានានៅក្នុងការបោះឆ្នោត នៅក្នុងពេលប្រជុំរបស់លោកជាមួយមន្ត្រីរដ្ឋាភិបាល ពាក់ព័ន្ធ គ.ជ.ប. និងអង្គការក្រៅរដ្ឋាភិបាលនានា។ ក្នុងការត្រៀមរៀបចំសំរាប់ការបោះឆ្នោតនេះ មានការធ្វើវិសោធកម្មយ៉ាងធំសម្បើមនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានអនុមតិកាលពីខែសីហា ឆ្នាំ ២០០២។ ទោះបីតំណាងពិសេសបានទទួលស្គាល់ថា មានការកែប្រែជាវិជ្ជមានជាច្រើនក៏ដោយ ក៏លោកនៅតែសំដែងការសោកស្តាយចំពោះវិសោធនកម្មនេះត្រូវបានអនុម័តដោយប្រញាប់ប្រញាល់ពេក ដោយពុំបានពិគ្រោះយោបល់ជាមួយសាធារណៈជនឱ្យបានច្រើនឡើយ។ ពិនិត្យពីសារៈសំខាន់ជាមូលដ្ឋាននៃសេរីភាពក្នុងការសំដែងមតិ និងសិទ្ធិក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានក្នុងពេលយុទ្ធនាការបោះឆ្នោត កិច្ចការជាចំបងមួយ របស់ គ.ជ.ប. និងរាជរដ្ឋាភិបាល គឺត្រូវធានាឱ្យគណបក្សនយោបាយទាំងអស់អាចប្រើប្រាស់ដោយស្មើភាពគ្នានូវប្រព័ន្ធផ្សព្វផ្សាយពត៌មានរបស់រដ្ឋ។ ហើយរាជរដ្ឋាភិបាល និងគ.ជ.ប. ក៏ត្រូវខិតខំដោយ

ពេញទំហឹងដើម្បីជំរុញការប្រើប្រាស់ដូចគ្នានេះ នូវប្រព័ន្ធផ្សព្វផ្សាយពត៌មានដែលមិនមែនជារបស់រដ្ឋជាពិសេស ប្រព័ន្ធផ្សព្វផ្សាយពត៌មានអេឡិចត្រូនិក។ តំណាងពិសេសបានជំរុញដល់សមាជិកគជបថ្មី សូមកុំឱ្យប្រព្រឹត្តនូវកំហុសដដែលដូចដែលគ.ជ.ប.ចាស់បានប្រព្រឹត្ត ដោយគេទទូចថា ការអនុញ្ញាតឱ្យប្រើប្រាស់ដោយស្មើភាពគ្នា អាចបណ្តាលឱ្យមានភាពច្របូកច្របល់ និងប្រជាពលរដ្ឋឆាប់រំជើបរំជួល។

៨- រហូតមកដល់ថ្ងៃទី ៣០ ខែវិច្ឆិកា តំណាងពិសេសបានជ្រាបថា មានចំនួន១០ក្នុងចំណោម១៧ករណីកាត់ឱ្យជាប់ទោសពីរឿងឃាតកម្មទាក់ទិននឹងការបោះឆ្នោត និងការស្លាប់ដែលមានការសង្ស័យដែលបានកត់ត្រាឃើញមុនការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០០២។ ចាប់តាំងពីការបោះឆ្នោតឃុំ/សង្កាត់ខែកុម្ភៈ រហូតដល់ចុងខែវិច្ឆិកា ឆ្នាំ ២០០២ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានស្រាវជ្រាវ និងកត់ត្រាទុកឃើញមានករណីចំនួន៨ គឺជាករណីឃាតកម្មទាក់ទិននឹងការបោះឆ្នោត។ ទាក់ទិននឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់នេះដែរ គ.ជ.ប. ខ្លួនឯងបានខកខានមិនបានប្រើប្រាស់នូវអំណាចដ៏ធំធេងដែលត្រូវបានប្រគល់ឱ្យខ្លួន តាមរយៈច្បាប់ស្តីពីការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់។ ទាក់ទិនទៅនឹងការបោះឆ្នោតនាពេលខាងមុខ តំណាងពិសេសសូមអំពាវនាវដល់ គ.ជ.ប. ថ្មី ក៏ដូចជាប្រព័ន្ធយុត្តិធម៌កម្ពុជា សូមឱ្យប្រើប្រាស់ភារកិច្ចស្របច្បាប់របស់ខ្លួនដើម្បីចាត់វិធានការ ប្រឆាំងនឹងបុគ្គលទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើហឹង្សា ការបំភិតបំភ័យ និងការជ្រៀតជ្រែកដទៃទៀត នៅក្នុងការប្រើប្រាស់ដោយសេរីនូវសិទ្ធិបោះឆ្នោត ឬក្នុងដំណើរការនៃការបោះឆ្នោតដោយត្រឹមត្រូវ។

៩- ការជួញដូរមនុស្សគឺជាបញ្ហាចំបងមួយដែលគួរឱ្យព្រួយបារម្ភនៅក្នុងប្រទេសកម្ពុជា ដោយសារជាប្រទេសដើមនៃការឆ្លងកាត់ និងជាទិសដៅនៃការជួញដូរនេះ។ អ្នកដែលទទួលផលប៉ះពាល់សំខាន់ជាងគេគឺស្ត្រី និងកុមារ ដែលត្រូវបង្ខំ ឬរុញច្រានឱ្យធ្លាក់ចូលទៅក្នុងពេស្យាកម្ម ជួលឬលក់ដែលជារឿយៗដោយឪពុកម្តាយឬសាច់ញាតិ ឬត្រូវគេចាប់ពង្រត់។ ការជួញដូរសំរាប់ទិសដៅឱ្យគេយកទៅធ្វើជាកូនចិញ្ចឹមក៏ជាបញ្ហាព្រួយបារម្ភដ៏ចំបងមួយដែរ។

១០- តំណាងពិសេសបានតាមដានចំពោះទស្សនៈកិច្ចកាលពីខែសីហា ឆ្នាំ ២០០២ របស់លោកស្រីអតីតឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស អ.ស.ប. ដែលបានគូសបញ្ជាក់អំពីការបារម្ភទាំងនេះនៅក្នុងពេលទស្សនៈកិច្ចរបស់លោកស្រី។ អំពើពុករលួយ និង ការខ្វះខាតនគរបាលសំរាប់ពង្រឹងការអនុវត្តច្បាប់

គឺជាកត្តារួមចំណែកដ៏សំខាន់មួយចំពោះការកើនឡើង នៃអាជីវកម្មផ្លូវភេទ ដែលបច្ចុប្បន្នជា "មុខរបរ" ខ្ពស់បំផុតទី៣ របស់ស្ត្រីនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីកសិកម្ម និងការកាត់ដេរ។ តំណាងពិសេស បានជំរុញដល់រាជរដ្ឋាភិបាល និងអាជ្ញាធរ សូមធានាឱ្យមានការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីអំពីការ ជួញដូរមនុស្ស ឱ្យមានប្រសិទ្ធភាព។

## II- ការវិវត្តន៍ជាចំបង និងបញ្ហាសិទ្ធិមនុស្សដែលគួរឱ្យព្រួយបារម្ភ

### ក- ការកែទម្រង់ប្រព័ន្ធយុត្តិធម៌

១១- ទោះបីជាមានសេចក្តីថ្លែងការណ៍ជាញឹកញាប់ ពីសំណាក់ថ្នាក់ខ្ពស់បំផុតរបស់រដ្ឋាភិបាលយ៉ាងណា ក៏ដោយ ក៏ការរីកចំរើនក្នុងការកែទម្រង់ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជានៅតែយឺត និងស្ថិតនៅជា បញ្ហាមួយគួឱ្យព្រួយបារម្ភដ៏ធ្ងន់ធ្ងរដដែល។ តុលាការមួយឯករាជ្យ ត្រឹមត្រូវ មានសមត្ថភាព និងប្រកប ដោយប្រសិទ្ធភាព គឺជាអ្វីដែលជាលក្ខខណ្ឌតម្រូវ ដើម្បីធានាសិទ្ធិមនុស្ស និងនីតិរដ្ឋ ក៏ដូចជាលក្ខខណ្ឌ សំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិនិយោគផងដែរ។ ការខ្វះតុលាការមួយដែលដំណើរការដោយត្រឹមត្រូវ ឯករាជ្យ និងមិនលំអៀង បន្តផ្តល់ផលប៉ះពាល់ដល់ការទទួលបាននូវសិទ្ធិមនុស្សទាំងឡាយ ដែលត្រូវបាន ធានាជូនប្រជាពលរដ្ឋកម្ពុជាដោយរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ និងឯកសារសិទ្ធិមនុស្សអន្តរជាតិនានា ដែល ប្រទេសកម្ពុជាជាភាគី។ ប្រព័ន្ធច្បាប់គ្រប់គ្រាន់ និងតុលាការមួយមិនរឹងមាំ ធ្វើឱ្យរាំងស្ទះដល់គំរោង ការងារ ការវិនិយោគបរទេសនាពេលអនាគត។ ផលប៉ះពាល់ទូទៅរួមចំណែកប្រព័ន្ធតុលាការ ក៏មាន ភាពអវិជ្ជមានដែរ ក្នុងការខិតខំកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល។

១២- នៅក្នុងពេលប្រជុំក្រុមប្រឹក្សាយោបល់នៃប្រទេសផ្តល់ជំនួយកាលពីខែមិថុនា ឆ្នាំ ២០០២ ប្រទេសផ្តល់ជំនួយ និងសហគមន៍អន្តរជាតិ បានលើកឡើងជាថ្មីម្តងទៀតនូវការព្រួយបារម្ភរបស់ពួកគេ អំពីការបន្តការរីកសាយនូវអំពើពុករលួយ និងស្ថានភាពជាទូទៅនៃប្រព័ន្ធតុលាការ។ ដើម្បីធានាឱ្យមាន ការរីកចំរើនជាអប្បបរិមាក្នុងវិស័យទាំងនេះ ប្រទេសផ្តល់ជំនួយ និងរដ្ឋាភិបាល បានយល់ស្របចំពោះ ការកំណត់រយៈពេលអនុវត្តមួយចំនួនតូច ដែលនៅមិនទាន់បំពេញបាននៅឡើយ។

១៣- ច្បាប់ដែលជាអាទិភាពដែលត្រូវបានកំណត់សំរាប់អនុវត្តន៏ រួមមានច្បាប់ស្ដីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ដែលចែងអំពីលក្ខខណ្ឌក្នុងបំរើការងារ និងរយៈពេលកាន់ដំណែងជាប់របស់ចៅក្រម និងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសាលាជំរះក្ដី ដែលមានគោលដៅរៀបចំរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការឡើងវិញ។ ការលំបាកនៅក្នុងប្រព័ន្ធតុលាការអាចរកឃើញថា មួយផ្នែកគឺដោយសាការខ្វះខាតនូវភាពច្បាស់លាស់នៅក្នុងយុត្តាធិការនៅគ្រប់ជាន់ថ្នាក់ និងនៅសាលាឧទ្ធរណ៏ដែលមានតែមួយគត។ ទោះជារដ្ឋាភិបាលប្រទេសផ្ដល់ជំនួយខ្លះ បានកៀបសង្កត់ឱ្យអនុម័តជាបន្ទាន់នូវច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ ដែលត្រូវបានរង់ចាំយូរណាស់មកហើយក៏ដោយ ក៏នៅទីបញ្ចប់អង្គប្រជុំបានឯកភាពគ្នាថាច្បាប់ដែលមានស្រាប់ត្រូវតែពង្រឹងអនុវត្តជាបន្ទាន់ ហើយកំណត់យកខែ មិថុនា ឆ្នាំ ២០០៣ ជាថ្ងៃអវសានវាទ សំរាប់អនុម័តច្បាប់ស្ដីពីការប្រឆាំងអំ ពើពុករលួយ។

១៤- តំណាងពិសេសបានកត់សំគាល់ឃើញអំពីវិធានការជាវិជ្ជមានខ្លះបានចាត់ឡើងដោយរដ្ឋាភិបាល។ ការផ្ដើមគំនិតមួយដើម្បីតម្លើងប្រាក់បំណាច់ និងប្រាក់ខែដល់ចៅក្រម និងព្រះរាជអាជ្ញា ត្រូវបានស្វាគមន៏។ អនុក្រិត្យមួយអនុម័តនៅខែវិច្ឆិកា ឆ្នាំ ២០០២ បានតម្លើងប្រាក់ខែពីប្រមាណ ២៥ ដុល្លារទៅ ៣០០ ជាអប្បបរិមាដុល្លារក្នុងមួយខែ។ ប៉ុន្ដែថវិកាជាតិសំរាប់វិស័យយុត្តិធមិ សំខាន់ត្រូវតែតម្លើងដែរបើសិនជាចង់អនុវត្តឱ្យមានចីរភាព។ តំណាងពិសេសសង្ឃឹមថា ការបង្កើនជាដុំកំភួននូវប្រាក់បំណាច់ និងប្រាក់ខែ មុខជានឹងជួយទប់ស្កាត់អំពើពុករលួយជាទូទៅនៅក្នុងប្រព័ន្ធតុលាការ ជាពុំខានឡើយ ប៉ុន្ដែសង្កត់ធ្ងន់ថាការនេះនឹងចាំបាច់ត្រូវឱ្យមានការចាត់វិធានការឱ្យបានសកម្ម ពីក្រុមព្រឹក្សាខាងវិន័យនៃឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម។

១៥- ដើម្បីធានាឯករាជភាពនៃតុលាការកម្ពុជា ដែលនៅតែងាយនឹងទទួលការជ្រៀតជ្រែកពីអំណាចនីតិប្រតិបត្តិ និងឥទ្ធិពលនយោបាយ តំណាងពិសេសបានអំពាវនាវដល់រដ្ឋាភិបាលសូមធ្វើការកែទម្រង់រចនាសម្ព័ន្ធឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាអង្គការដែលត្រូវបានការទុកចិត្ត ប្រគល់ភារកិច្ចក្នុងការធានាឯករាជភាពនៃតុលាការ និងរក្សាវិន័យចៅក្រម និងព្រះរាជអាជ្ញា។ ការនេះទាមទារឱ្យធ្វើការពិនិត្យឡើងវិញទាំងស្រុងនូវច្បាប់ដែលមានស្រាប់ និងបញ្ចូលវិធានការប្រកបដោយប្រសិទ្ធភាពដែលនាំឱ្យមានការផ្លាស់ប្ដូរទី១ និងមុនគេបង្អស់គឺត្រូវធានាឯករាជភាពរបស់ក្រុមប្រឹក្សាខ្លួនឯង។ សេចក្ដីព្រាងច្បាប់វិសោធនកម្មបច្ចុប្បន្ន ដែលបានដាក់ជូនរដ្ឋសភាហើយនោះ មិនបានលើកអំពីការកែទម្រង់រចនាសម្ព័ន្ធណាមួយនៃក្រុមប្រឹក្សាទេ។

១៦- អ្វីដែលមានសារៈសំខាន់ដូចគ្នានេះដែរ គឺការធ្វើវិសោធនកម្មលើមាត្រា ១៥ នៃច្បាប់ស្តីពីគណបក្សនយោបាយ ដើម្បីផ្តាច់សមាជិកក្រុមប្រឹក្សាចៅក្រម និងព្រះរាជអាជ្ញាចេញ ពីគណបក្សនយោបាយ។ បញ្ហានេះត្រូវបានលើកឡើងជាញឹកញាប់ ដោយតំណាងពិសេស ជាមួយអាជ្ញាធរពាក់ព័ន្ធ ហើយនៅក្នុងឱកាសអញ្ជើញមកបំពេញបេសកកម្មថ្មីៗបំផុតនេះរបស់លោក បានលើកឡើងជាមួយក្រុមប្រឹក្សាសំរាប់ធ្វើការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការដែលទើបបង្កើតថ្មី។

១៧- ក្រុមប្រឹក្សានេះ បានបង្កើតឡើងមួយថ្ងៃមុនថ្ងៃប្រជុំក្រុមប្រឹក្សាយោបល់នៃប្រទេសផ្តល់ជំនួយកាលពីខែមិថុនា ឆ្នាំ ២០០២ ដើម្បីធ្វើជាយានជំរុញ និងតាមដានពិនិត្យការអនុវត្តកិច្ចដំណើរការនៃការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍មួយត្រូវបានបង្កើតឡើងដោយអនុក្រិត្យកាលពីខែសីហា ឆ្នាំ ២០០២ ដើម្បីជួយក្រុមប្រឹក្សាថ្មីនេះ។ ឯកសារយុទ្ធសាស្ត្រ និងផែនការសកម្មភាពសំរាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានរង់ចាំជាយូរណាស់មកហើយ ដែលជាផែនការមូលដ្ឋានសំរាប់ការផ្លាស់ប្តូរ នៅមិនទាន់បានបញ្ចប់នៅឡើយទេ និងត្រូវតែផ្តល់អាទិភាពខ្ពស់ដល់វា។

១៨- មានការអភិវឌ្ឍន៍ជាវិជ្ជមានខ្លះ ត្រូវបានកត់សំគាល់ឃើញក្នុងការខិតខំប្រឹងប្រែងដើម្បីបង្កើនសមត្ថភាពដល់ចៅក្រម និងព្រះរាជអាជ្ញា។ ប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពនៃសាលាភូមិន្ទទើបបង្កើតថ្មី សំរាប់ហ្វឹកហ្វឺនដល់ចៅក្រម និងព្រះរាជអាជ្ញា អាចនឹងមានអំណោយផលល្អដល់គុណភាព នៃការគ្រប់គ្រងផ្នែកយុត្តិធម៌ក្នុងរយៈពេលយូរអង្វែង។

១៩- តម្រូវការមេធាវីដែលមានសមត្ថភាព ដើម្បីធានាការផ្តល់យុត្តិធម៌ជូនដល់ប្រជាពលរដ្ឋនៃប្រទេសកម្ពុជា
និងពហុតួនាទីរបស់គណៈមេធាវីអាចដើរតួក្នុងការពង្រឹងប្រព័ន្ធតុលាការនៅមិនទាន់ធ្វើការវាយតម្លៃបានសមស្របនៅឡើយទេ។ ព្រមជាមួយនឹងការបង្កើតនូវមណ្ឌលហ្វឹកហ្វឺនមេធាវីនាពេលថ្មីៗនេះ ដែលបានចាប់ផ្តើមកម្មវិធីហ្វឹកហ្វឺននិស្សិត ដែលទើបទទួលបានសញ្ញាប័ត្រច្បាប់ថ្មីៗចំនួន៦០នាក់ កាលពីខែតុលា ឆ្នាំ២០០២ នេះជាសេចក្តីសង្ឃឹមថាជំនាន់ថ្មីមួយនៃមេធាវីដែលមានការហ្វឹកហ្វឺនជាអាជីព នឹង

ត្រូវបានចូលទៅក្នុងគណៈមេធាវី។ តែទោះបីជាដូចនេះក្តី តំណាងពិសេសនៅតែបន្តមានការព្រួយបារម្ភជាបន្តទៀតអំពីបញ្ហាការខ្វះខាតមេធាវីជាប្រចាំនៅក្នុងប្រទេសកម្ពុជា។

២០- នៅប្រទេសកម្ពុជាមានតុលាការជាច្រើនដែលគ្មានមេធាវីសំរាប់ការពារក្តី។ ក្នុងប្រទេសមួយដែលមានប្រជាពលរដ្ឋជាង ១២ លាននាក់ មានមេធាវីអនុវត្តច្បាប់មិនដល់ ២០០ នាក់ផង ហើយក្នុងនេះមានតែ ២០ នាក់ប៉ុណ្ណោះធ្វើការនៅតាមខេត្តនានា។ ឧទាហរណ៍ នៅថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០២ ជាលើកទី ១ ហើយនៅក្នុងប្រវត្តិសាស្ត្រតុលាការខេត្តព្រះវិហារ តំណាងខាងច្បាប់ត្រូវបានផ្តល់ឱ្យដោយមេធាវីការពារម្នាក់ពីអង្គការគំរោងការអ្នកការពារក្តីកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយ ដើម្បីតំណាងឱ្យអតិថិជននៅក្នុងករណីព្រហ្មទ័ណ្ឌមួយ។ ទោះបីមានការខ្វះខាតមេធាវីយ៉ាងដូច្នេះក៏ដោយ ក៏គណៈមេធាវីបន្តបកស្រាយដោយចង្អៀតចង្អល់មាត្រា៣២ នៃច្បាប់ស្តីគណៈមេធាវី ដោយរឹតបន្តឹងតែង ការអនុញ្ញាតឱ្យនិស្សិតក្មេងដែលទើបនឹងទទួលបានសញ្ញាប័ត្រច្បាប់ចូលក្នុងគណៈមេធាវី។ ក្នុងពេលអញ្ជើញមកបំពេញបេសកកម្មលើកទី៧របស់លោក តំណាងពិសេសបានលើកឡើងជាថ្មី អំពីការព្រួយបារម្ភទាំងនេះក្នុងពេលប្រជុំជាមួយក្រុមប្រឹក្សា គណៈមេធាវីដែលជ្រើសតាំងថ្មី និងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ លោកបានជំរុញជាថ្មី សូមឱ្យពង្រីកវិសាលភាពនៃច្បាប់ និងកែលំអរការផ្តល់យុត្តិធម៌ដល់ជនក្រីក្រតាមផ្លូវតុលាការ។ លោកក៏បានលើកទឹក ចិត្តដល់រដ្ឋាភិបាលផងដែរឱ្យបង្កើតមូលនិធិសំរាប់ការពារជនក្រីក្រ ដើម្បីផ្តល់សេវាខាងផ្លូវច្បាប់ដល់ប្រជាពលរដ្ឋក្រីក្រ និងនៅជនបទ។

២១- ទោះបីមានការរីកចំរើនយឺតក្នុងការប្រកាសអំពីអាទិភាពច្បាប់ក៏ដោយ ក៏តំណាងពិសេសបានកត់សំគាល់ឃើញមានការរីកចំរើន ក្នុងការធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីដោយ មានជំនួយពីរដ្ឋាភិបាលជប៉ុន។ ក្រុមការងារនៃអ្នកជំនាញការច្បាប់ជប៉ុន បានប្រមើលទុកជាមុនថា សេចក្តីព្រាងចុងក្រោយនៃក្រមទាំងនេះនឹងធ្វើចប់នៅចុងខែមិនា ឆ្នាំ ២០០៣។ ប្រការសំខាន់បំផុតគឺត្រូវពិនិត្យឡើងវិញដើម្បីឱ្យសេចក្តីព្រាងទាំងនេះធ្វើវារលូនជាមួយច្បាប់សំខាន់ៗដទៃទៀត ដូចជាច្បាប់ភូមិបាល ច្បាប់ព្រៃឈើ និងច្បាប់ពាណិជ្ជកម្មអនុម័តថ្មីៗ និងដើម្បីទុកពេលវេលាសំរាប់ការពិភាក្សាពិគ្រោះយោបល់ជាមួយសាធារណៈមតិឱ្យបានពេញលេញ។ សេចក្តីព្រាងក្រមព្រហ្មទ័ណ្ឌ និងក្រមនីតិវិធីព្រហ្មទ័ណ្ឌក៏ដូចគ្នាដែរ ឥឡូវនេះឈានចូលដល់ដំណាក់កាលចុងបញ្ចប់ហើយ ហើយក៏ត្រូវឱ្យ

មានការយកទៅពិគ្រោះពិភាក្សាយោបល់ ដោយពេញលេញពីសំណាក់សាធារណៈជនផងដែរ មុនដាក់ជូនរដ្ឋសភា។

២២- តំណាងពិសេសស្វាគមន៍ការផ្តើមគំនិតកាលពីពេលថ្មីៗនេះ ធ្វើឡើងដោយគណៈកម្មការរដ្ឋ សភា និងក្រសួងនានាមួយចំនួននៃរដ្ឋាភិបាល ក្នុងការរៀបចំការប្រជុំពិគ្រោះយោបល់ជាសាធារណៈជន ដើម្បីពិភាក្សាសេចក្តីព្រាងច្បាប់ ឧទាហរណ៍ច្បាប់ស្តីពីហឹង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីការជួញដូរមនុស្ស ហើយសង្ឃឹមថា ការផ្តើមគំនិតទាំងនេះត្រូវរៀបចំឱ្យទៅជាច្បាប់។

២៣- តំណាងពិសេស បានពិនិត្យដោយជិតដល់ចំពោះការវិវឌ្ឍន៍ក្នុងការឆ្លើយតបទៅនឹងវិធានការដែលបានចាត់ឡើងដោយសហភាពអន្តរសភា លើករណីបណ្តេញព្រឹទ្ធសមាជិកកម្ពុជា៣នាក់ចេញពីព្រឹទ្ធសភាកាលពីខែធ្នូ ឆ្នាំ ២០០១។ ចំពោះបញ្ហាសិទ្ធិរបស់សមាជិកសភា ក្នុងការប្រើប្រាស់សេរីភាពក្នុងការនិយាយស្តី និងសំដែងមតិ តំណាងពិសេសបានទទួលការធានាពីសំណាក់ប្រធានរដ្ឋសភាថានឹងគ្មានការអនុវត្តវិធានការបែបនេះ ចំពោះសមាជិកសភាណាម្នាក់ឡើយ។ លោកសង្ឃឹមថាព្រឹទ្ធសភានឹងធ្វើដូចគ្នានេះដែរ ហើយជំរុញឱ្យព្រឹទ្ធសភាធ្វើតាមសេចក្តីសំរេចចិត្តថ្មីៗបំផុត អនុម័តដោយសហភាពអន្តរសភាកាលពីថ្ងៃទី ២៧ ខែកញ្ញាចំពោះបញ្ហានេះ។

## ខ- បញ្ហានិទ័ណ្ឌភាព

១) ការកាត់ក្តីនៅខេត្តកំពង់ចាម

២៤- តំណាងពិសេសមានការព្រួយបារម្ភយ៉ាងខ្លាំងបំផុត ចំពោះបញ្ហានិទ័ណ្ឌភាព នៅក្នុងប្រទេសកម្ពុជា។ បុគ្គលប្រើប្រាស់អំណាចរដ្ឋ ជាពិសេសមន្ត្រីប្រតិបត្តិច្បាប់ និងសមាជិកកម្លាំងប្រដាប់អាវុធ ត្រូវបានចាប់ឱ្យទទួលខុសត្រូវតិចតួចណាស់ចំពោះឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត។

២៥- នៅក្នុងការកាត់ក្តីមួយនៅក្នុងខេត្តកំពង់ចាម នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០២ ឆ្មាំពន្ធនាគារចំនួន៥នាក់ បានប្រឈមមុខនឹងការចោទប្រកាន់ពីបទរំលោភលើសិទ្ធិបុគ្គលកាលពីឆ្នាំ ១៩៩៩ ដោយពួកគេបានវាយដំអ្នកទោស៥នាក់យ៉ាងធ្ងន់ធ្ងរ បន្ទាប់ពីពួកគេបានប៉ុនប៉ងរត់ចេញពីពន្ធនាគារ។ តាមចម្លើយ

ជាសាក្សីរបស់អ្នកទោសដទៃទៀត និងពីជនរងគ្រោះផ្ទាល់ ជនទាំង៥នាក់នេះត្រូវបានទទួលរងការវាយដំយ៉ាងខ្លាំងដោយក្រុមឆ្មាំពន្ធនាគារ។ តាមការចោទប្រកាន់ ដែលមិនទាន់មានភស្តុតាង ការវាយដំនេះបានធ្វើឡើងនៅចំពោះមុខមន្ត្រីពន្ធនាគារ ក្នុងនេះរួមមាននាយកពន្ធនាគារ និងគ្រូពេទ្យផង ហើយអ្នកទោសដទៃទៀតបានឃើញដោយផ្ទាល់។ ឆ្មាំម្នាក់បានថ្លែងនៅក្នុងចម្លើយរបស់គេចំពោះចៅក្រមស៊ើបអង្កេតថា គេបានវាយដំនេះ គឺធ្វើតាមបញ្ជារបស់នាយកពន្ធនាគារ។ ជនរងគ្រោះទាំង៥នាក់ត្រូវបានវាយជាច្រើនដំបង ដោយប្រើដងចបកាប់ ឬដំបងឈើផ្សេងទៀត ហើយអ្នកខ្លះត្រូវគេដាល់ ទាត់ធាក់ទះកំភ្លៀង ឬវាយក្បាលនឹងជុំថ្ម។

២៦- បន្ទាប់មកមានជនរងគ្រោះចំនួន២នាក់យ៉ាងតិច ដែលពេទ្យពន្ធនាគារ មិនផ្តល់ការព្យាបាលឱ្យ។ ប្រមាណជា២អាទិត្យក្រោយការវាយដំជនទាំង៥នាក់នេះ ត្រូវសម្រាតឱ្យនៅតែខោអាវក្នុង ហើយដេកដោយគ្មានពូក ភួយ និងមុង។ របបហូបចុកត្រូវបានកាត់បន្ថយ ហើយត្រូវគេដាក់ឱ្យនៅក្នុងបន្ទប់២៤ម៉ោងក្នុងមួយថ្ងៃ ដោយរំលោភលើបទបញ្ជាផ្ទៃក្នុងពន្ធនាគារ ហើយការនេះបានកើតមានក្នុងពេលមួយខែបន្ទាប់ពីការវាយដំ។ ការបង្អត់មិនឱ្យងូតទឹក ធ្វើឱ្យអ្នកខ្លះមានជម្ងឺស្បែក។ មួយខែក្រោយមកនៅពេលសម្ភាសន៍ជាមួយអង្គការលីកាដូ៤នាក់ក្នុងចំណោមអ្នកទាំង៥នាក់នេះ ឃើញនៅមានស្នាមរបួសឬក្រម៉ៅនៅឡើយ ហើយម្នាក់ដើរដោយលំបាក។

២៧- ទោះបីមានភស្តុតាងបង្ហាញជូនចំពោះមុខតុលាការ ព្រមទាំងមានចម្លើយសារភាពពីជនរងគ្រោះ និង អ្នកទោសដទៃទៀត ដែលបានឃើញព្រឹត្តិការណ៍នេះក៏ដោយ ក៏ចុងចោទទាំង៥នាក់ត្រូវបានកាត់ឱ្យរួចខ្លួន។ ប៉ុន្តែតុលាការបានបង្វែរទៅជាការដាក់វិធានការរដ្ឋបាលចំពោះជនទាំងនេះទៅវិញ។ រហូតមកដល់ដំណាច់ខែវិច្ឆិកាឆ្នាំ២០០២ នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ នៅមិនទាន់ឃើញមានចាត់វិធានការ បែបនៅឡើយទេ។ នៅពេលជាមួយគ្នានោះ ចុងចោទ៣នាក់ នៅតែបន្តធ្វើការនៅក្នុងពន្ធនាគារខេត្តកំពង់ចាមជាដដែល ហាក់បីដូចជាពួកគេមិនមានជាប់ពាក់ព័ន្ធ នឹងឧប្បត្តិហេតុនេះអ្វីទេ។

២) ការសម្លាប់ដោយហ្វូងមនុស្ស

២៨- ដោយមានការកើនឡើងនៃការសម្លាប់ដោយហ្វូងមនុស្ស បណ្តាលឱ្យតំណាងពិសេសចេញផ្សាយរបាយការណ៍មួយ នៅខែមិថុនា ឆ្នាំ២០០២ ក្រោមចំណងជើងថា "ការចងពៀរនៅតាមដងផ្លូវនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ ផ្អែកតាមការកត់ត្រាឯកសារពីករណីវាយតប់ និងករណីឃាតកម្មដែលកើតឡើងដោយហ្វូងមនុស្សចំនួន៦៥លើក ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៩៩មក។ របាយការណ៍បានថែងថាជារឿយៗ មន្ត្រីពង្រឹងអនុវត្តច្បាប់ខកខានមិនបានធ្វើអន្តរាគមន៍ដើម្បីបញ្ឈប់អំពើហឹង្សាបែបនេះ ហើយថាពួកបានឃុប ឃិតដោយផ្ទាល់នៅក្នុងឱកាសជាច្រើន។ នៅក្នុងរបាយការណ៍របស់លោក តំណាងពិសេសបានសុំឱ្យបង្កើតអង្គការស៊ើបអង្កេតឯករាជ្យមួយ ដើម្បីវាយតម្លៃថាតើហេតុអ្វីបានជាកើតមានការសម្លាប់ដោយហ្វូងមនុស្ស និងធ្វើដូចម្តេចដើម្បីទប់ស្កាត់កុំឱ្យវាកើតមានឡើងបាន។

២៩- តំណាងពិសេសសង្ឃឹមថា អង្គការមួយបែបនេះនឹងត្រូវបង្កើតឡើងដោយរដ្ឋាភិបាល។ លោកសូមស្វាគមន៍ការដែលចំនួនការសម្លាប់ដោយហ្វូងមនុស្ស បានថយចុះចាប់តាំងពីលោកបានចេញផ្សាយរបាយការណ៍នេះមក។ ចាប់ពីដើមខែមិថុនា ដល់ចុងខែវិច្ឆិកាឆ្នាំ២០០២មក ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស បានកត់ត្រាឃើញមានតែ២ករណីប៉ុណ្ណោះ។

## គ- ពន្ធនាគារ

៣០- ក្នុងពេលទស្សនៈកិច្ចរបស់លោក តំណាងពិសេសបានជួបសន្ទនាជាមួយអាជ្ញាធរពន្ធនាគារ មន្ត្រីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ស្តីពីគោលនយោបាយពន្ធនាគារដែលប្រកបដោយមនុស្សធម៌ជាងនេះសំរាប់ប្រទេសកម្ពុជា ដោយផ្អែកលើឯកសារព្រាងសំរាប់ពិភាក្សា ដែលសង្ខេបអំពីការប្រែប្រួលលក្ខណៈដែលបានកើតមានឡើងតាំងពីឆ្នាំ១៩៩៤មក នៅពេលដែលការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានចេញផ្សាយនូវរបាយការណ៍មួយក្រោមចំណងជើងថា "ស្ថានភាពពន្ធនាគារកម្ពុជា"។

៣១- ចាប់តាំងពីរបាយការណ៍នេះ ត្រូវបានចេញផ្សាយមក ចំនួនអ្នកទោសនៅក្នុងពន្ធនាគារបានកើនឡើង៣ដង។ សព្វថ្ងៃពន្ធនាគារជាច្រើន ផ្ទុកមនុស្សច្រើនហួសដែលអាចនាំឱ្យមានគ្រោះថ្នាក់។ ទំហំកន្លែងរស់នៅនៅក្នុងពន្ធនាគារនៅខេត្តកំពង់ធំជាដើម គឺតិចជាង១ម៉ែត្រក្រឡាសំរាប់អ្នកទោសម្នាក់។

៣២- ការផ្តន្ទាទោសដាក់ពន្ធនាគារ គឺជាទម្លាប់ធម្មតាសំរាប់បទល្មើសព្រហ្មទណ្ឌភាគច្រើន។ ការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនអ្នកទោនៅក្នុងពន្ធនាគារ អាចនឹងដោះស្រាយទៅបានដោយដាក់បញ្ចូលនូវការអនុវត្តការផ្តន្ទាទោស ដោយមិនបាច់ដាក់ពន្ធនាគារជាជំនួសវិញ។ ឧទាហរណ៏ មានការប្រើប្រាស់តិចតួចណាស់នូវការផាកពិន័យ និងការព្យួរទោស មិនមានប្រើប្រាស់សេវាសហគមន៍ជាជំនួសចំពោះអនីតិជន និងអ្នកដែលទើបតែប្រព្រឹត្តកំហុសជាលើកទី១នោះទេ។ មនុស្សជាប់ចោទ តែងតែត្រូវឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ក្តីក្នុងរយៈពេលយូរ ទោះបីជាបទល្មើសព្រហ្មទណ្ឌ ដែលខ្លួនត្រូវចោទនោះមាន លក្ខណៈស្រាលក៏ដោយ។

៣៣- ការដាក់មនុស្សច្រើនពេកនៅក្នុងពន្ធនាគារ គឺជាការគំរាមកំហែងដល់សុខភាពអ្នកទោស ដោយវាបង្កើនឱ្យមានការរីករាលដាលនៃជម្ងឺខ្លះ ដូចជាជម្ងឺកមរមាស់ និងជម្ងឺរបេងជាដើម។ សុខភាពក៏ត្រូវបានបំផ្លាញដ៏ធ្ងន់ធ្ងរ ដោយសារការខ្វះអាហារ និងទឹកស្អាត។ បញ្ហាទាំងនេះមានការកែប្រែតិចតួចណាស់ក្នុងរយៈពេល៨ឆ្នាំកន្លងទៅនេះ។ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសំរាប់អាហារដល់អ្នកទោសម្នាក់ៗ ស្ថិតនៅដដែលចាប់តាំងពីឆ្នាំ១៩៩៤មក គឺ១000រៀល ឬប្រមាណ២៥សេនដុល្លារប៉ុណ្ណោះ។

៣៤- សមបទដ្ឋានអន្តរជាតិគឺតម្រូវឱ្យអ្នកទោស ដែលមានជម្ងឺឱ្យព្យាបាលដោយគ្រូពេទ្យឯកទេសត្រូវតែបញ្ជូនគេទៅឱ្យស្ថាប័ន ឬមន្ទីរពេទ្យជំនាញ បញ្ហានេះសឹងតែមិនមានអ្វីកែប្រែទេ ហើយធ្វើដោយយឺតយ៉ាវណាស់នៅក្នុងប្រទេសកម្ពុជា។ ជារឿយៗ អ្នកទោសត្រូវគេបញ្ជូនទៅកាន់មន្ទីរពេទ្យ តែនៅពេលដែលដឹងច្បាស់ថា គេជិតស្លាប់ប៉ុណ្ណោះ ទោះជាការបញ្ជូនទៅមុនពេល និងបើសិនជាមានការយកចិត្តទុកដាក់ព្យាបាលផ្នែកពេទ្យត្រឹមត្រូវ អាចនឹងសង្គ្រោះជីវិតពួកគេបានក៏ដោយ។ គេច្រើនតែលើកយកបញ្ហាការខ្វះថវិការ សំរាប់ការដឹកជញ្ជូន និងការខ្វះឆ្នាំ មកប្រើជាលេស។ អ្នកទោសជាច្រើនត្រូវពឹងផ្អែកលើអង្គការក្រៅរដ្ឋាភិបាល ធានាក្នុងការរក្សាថែទាំសុខភាពជាមូលដ្ឋាន។

៣៥- ការខ្វះខាតក្នុងការផ្តល់ការដឹកជញ្ជូនអ្នកទោស ក៏ជាបច្ច័យអវិជ្ជមានសំរាប់កិច្ចដំណើរការរបស់តុលាការផងដែរ។ ជារឿយៗ សវនាការរបស់តុលាការត្រូវលើកពេល ដោយសារអ្នកទោសពុំមានលទ្ធភាពចូលខ្លួនមកកាន់សវនាការតុលាការ។ ចំពោះករណីដទៃទៀត សវនាការត្រូវធ្វើដោយកំបាំងមុខ។ ជាក់ស្តែងនៅក្នុងបញ្ហាទាក់ទិននឹងការដឹកជញ្ជូននេះ ក៏បានធ្វើឱ្យអ្នកទោសមិនអាចប្តឹងឧទ្ធរណ៏ដែរ។ បច្ចុប្បន្ន មានសាលាឧទ្ធរណ៏ និងតុលាការកំពូល មានតែមួយនៅភ្នំពេញប៉ុណ្ណោះ។ ការ

បង្កើតតុលាការឧទ្ធរណ៍នៅតាមភូមិភាគ ឬដែលអាចចល័តបានពីមួយកន្លែងទៅកន្លែងផ្សេងទៀត នឹងអាចជួយធានាដល់សិទ្ធិរបស់អ្នកទោស ដើម្បីប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសំរេចរបស់ តុលាការថ្នាក់ទាប ។

៣៦- អាគារពន្ធនាគារភាគច្រើនមានសភាពចាស់ និងសភាពទ្រុឌទ្រោមយ៉ាងខ្លាំង ។ ភាគច្រើនមិនមានរបងមាំទាំគ្រប់គ្រាន់ដើម្បីការពារបរិវេណពន្ធនាគារទេ ។ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ អ្នកទោសទាំងអស់ត្រូវមានសិទ្ធិចេញទៅកាន់ទីធ្លា យ៉ាងតិចណាស់ឱ្យបានមួយម៉ោងក្នុងមួយថ្ងៃ តែបទបញ្ជាត្រូវបានធ្វើមិនដឹងមិនឮជាទូទៅ ។ បទបញ្ជាស្តីពីបទដ្ឋានជាអប្បបរិមារបស់អង្គការសហប្រជាជាតិសំរាប់គ្រប់គ្រងអ្នកទោសចែងថា អ្នកទោសភេទស្រីត្រូវតែដាក់ឱ្យនៅដាច់ដោយឡែកពីអ្នកទោសភេទប្រុស អ្នកទោសក្មេងត្រូវឱ្យនៅដាច់ដោយឡែកពីមនុស្សពេញវ័យ ហើយពិរុទ្ធជនត្រូវនៅដាច់ដោយឡែកពីទណ្ឌិត ។ ពន្ធនាគារដែលនៅក្រៅទីក្រុងភ្នំពេញ មិនសូវអនុវត្តតាមបទបញ្ជានេះទេ ។ ទោះបីជាអ្នកទោសបុរស និងស្ត្រី ត្រូវដាក់ឱ្យនៅក្នុងបន្ទប់ផ្សេងគ្នាហើយក៏ដោយ នៅពេលចេញក្រៅបន្ទប់ពួកគេបានចូលលាយឡំគ្នាដោយសេរី ។ នៅតាមពន្ធនាគារជាច្រើន ក្មេងៗ ត្រូវដាក់ឱ្យនៅជាមួយមនុស្សធំ ។ កន្លងទៅនេះមានការខិតខំប្រឹងប្រែងតិចតួចតែប៉ុណ្ណោះ ឬពុំមានទាល់តែសោះ ក្នុងការបំបែកឱ្យបានដាច់ដោយឡែកពីគ្នា រវាងអ្នកទោសព្រហ្មទណ្ឌក៏រិតស្រាល និងអ្នកទោសឧក្រិដ្ឋ ឬអ្នកទោសជាប់ឃុំបណ្តោះអាសន្ន រងចាំការជំរះក្តីឱ្យដាច់ចេញពីទណ្ឌិត និងប្រែក្លាយពន្ធនាគាររបស់កម្ពុជា ឱ្យទៅជាសាលាបណ្តុះបណ្តាលឧក្រិដ្ឋកម្ម ដ៏មានសក្តានុពលសំរាប់ក្មេងៗ និងជនទន់ខ្សោយ ។ ដោយសារការខ្វះខាតជាសុប្បករណ៏មិនគ្រប់គ្រាន់ ជាផលវិបាកដ៏ធំមួយ ការដាក់អ្នកទោសទាំងអស់ឱ្យនៅចំរុះគ្នាក៏បង្កើតនូវសត្តានុភាពនាំឱ្យមានការរំលោភខាងផ្លូវភេទ និងខាងផ្លូវចិត្តផងដែរ ។

៣៧- របាយការណ៏នានា បានបង្ហាញថាទារុណកម្ម និងប្រព្រឹត្តកម្មដទៃដែលសាហាវព្រៃផ្សៃអមនុស្សធម៌ បន្ទាបបន្ថោក ឬការផ្តន្ទាទោសនៅក្នុងពន្ធនាគារ បានចុះថយចាប់ពីឆ្នាំ១៩៩៤មក ។ ប៉ុន្តែឧប្បត្តិហេតុនេះ នៅតែបន្តកត់ត្រាឃើញ ហើយដែលគួរឱ្យព្រួយបារម្ភជាងគេនោះ គឺពុំមានអ្នកប្រព្រឹត្តកំហុសបែបនេះណាម្នាក់ត្រូវបានផ្តន្ទាទោសនៅឡើយទេ ចាប់តាំងពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ចាប់ផ្តើមធ្វើការតាមដានត្រួតពិនិត្យពន្ធនាគារ ចាប់ពីឆ្នាំ១៩៩៤មក ។

៣៨- តំណាងពិសេសក៏មានការព្រួយបារម្ភផងដែរដែលថា ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គកាក្រៅរដ្ឋាភិបាល បានប្រឈមមុខនឹងការ លំបាកដ៏ធ្ងន់ធ្ងរ ហើយដែលចេះ

តែកើនឡើងក្នុងការសុំចូលជួបអ្នកទោស។ ការជួបសម្ភាសន៍ជាឯកជន ជាមួយអ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យទេ បណ្តាលឱ្យមានបញ្ហាក្នុងការប្រមូលពត៌មានដែលគួរឱ្យជឿ ទុកចិត្តបានស្តីពីប្រព្រឹត្តកម្មចំពោះអ្នកទោស។ មេធាវីការពារក៏បានត្អូញត្អែផងដែរថា មន្ត្រីពន្ធនាគារខាយាំងមិនឱ្យចូលជួបកូនក្តីដោយមានការកំណត់ពេលវេលាក្នុងការជួប ឬទាមទារឱ្យមានលិខិត អនុញ្ញាតពិសេសដែលលំបាកសុំមិនងាយបាន។ ការសុំចូលសួរសុខទុក្ខអ្នកទោសដោយក្រុមគ្រួសារ និង មិត្តភក្តិ មានការពិបាកខ្លាំងណាស់ មិនគ្រាន់តែដើម្បីជួយគាំទ្រខាងផ្លូវចិត្តទេ សូម្បីតែដើម្បីផ្តល់អាហារ និងសម្ភារៈសំខាន់ៗផ្សេងទៀត ក៏ដូចជាដើម្បីជួយឱ្យវិលត្រឡប់មករួមរស់នៅសង្គមវិញ នៅពេលក្រោយ ពីជាប់ពន្ធនាគារគ្រប់តាមពេលកំណត់ទោសហើយ ក៏មានបញ្ហាលំបាកដែរ។ បទបញ្ជាជាធរមានចែងថា អ្នកទោសទាំងអស់ត្រូវមានសិទ្ធិទទួលការចូលមកសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ និងមិត្តភក្តិ យ៉ាងហោចណាស់ក៏បានមួយម៉ោងដែរក្នុងមួយអាទិត្យ។ បទបញ្ញត្តិនេះត្រូវបានធ្វើមិនដឹងមិនឮតៗគ្នា។ ក្នុងការអនុវត្តជាក់ស្តែង ក្រុមគ្រួសារភាគច្រើនអាចចូលជួបបាន ត្រឹមតែលើស១៥នាទីបន្តិចប៉ុណ្ណោះ ក្នុងមួយអាទិត្យ។

៣៩- ការឃុំខ្លួនជាបណ្តោះអាសន្ន មុនពេលជំនុំជំរះហួសរយៈពេលកំណត់ ស្ថិតនៅជាបញ្ហាធ្ងន់ធ្ងរ និងជាបន្ទាន់ ដែលនៅតាមតំបន់មួយចំនួននៃប្រទេស។ ច្បាប់កម្ពុជាចែងថា រយៈពេលឃុំខ្លួនជាបណ្តោះអាសន្នមុនពេលជំនុំជំរះមិនត្រូវលើសពី៤ខែទេ ប៉ុន្តែរយៈពេលនេះអាចពន្យាររហូតដល់រហូតដល់៦ខែ បើជាមានការចាំបាច់តម្រូវឱ្យការធ្វើការស៊ើបអង្កេត។ រហូតមកដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០២ មានអ្នកទោសចំនួន ២០៥ នាក់ នៅភ្នំពេញ និងខេត្តបន្ទាយមានជ័យ ដែលនៅជាប់ឃុំខ្លួនជាបណ្តោះអាសន្នមុនពេលជំនុំជំរះក្តីលើសពី៦ខែ។ មូលហេតុនៃការជាប់ឃុំហួសរយៈពេលកំណត់ ជារួមគឺដោយសារតុលាការមានរឿងដែលត្រូវដោះស្រាយច្រើនពេក និងការខ្វះខាតមធ្យោបាយសំរាប់ការដឹកជញ្ជូនពីពន្ធនាគារ។

៤០- តំណាងពិសេសត្រូវបានការលើកទឹកចិត្តដោយការឆ្លើយតបរបស់មន្ត្រីរដ្ឋាភិបាល នៅក្នុងអង្គសិក្ខាសាលាកាលពីខែវិច្ឆិកា ហើយសង្ឃឹមថាគោលនយោបាយពន្ធនាគារ ដែលប្រកបដោយមនុស្សធម៌ជាងនេះមួយ នឹងចេញជាលទ្ធផលពីសន្ទនាគ្នា ដែលត្រូវបានផ្តើមគំនិតរួចមកហើយនេះ។

## ឃ- ការបោះឆ្នោត

៤១- ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រលើកទី៣ របស់ប្រទេសកម្ពុជា ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១មក ត្រូវគ្រោងធ្វើនៅថ្ងៃទី២៧ ខែកក្កដាឆ្នាំ ២០០៣។ ក្នុងការរៀបចំការបោះឆ្នោតនេះ មានការធ្វើវិសោធនកម្មដ៏ច្រើនសម្បើមមួយលើច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានអនុម័តកាលពីខែសីហា ឆ្នាំ២០០២។ វិសោធនកម្មទាំងនេះបានកាត់បន្ថយចំនួនសមាជិកនៃគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត ពី១១នាក់ មកត្រឹម៥នាក់ប៉ុណ្ណោះ ស្ថាប័ននេះទទួលខុសត្រូវចំពោះការគ្រប់គ្រងការបោះឆ្នោត។ វិសោធនកម្មក៏បានបញ្ចូលប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតថ្មីមួយ ដែលរំពឹងថានឹងអាចឱ្យសន្សំប្រាក់បានដ៏ច្រើនសម្បើម។ ទោះបីជាទទួលស្គាល់ថាវិសោធនកម្មនេះ មានការកែប្រែជាវិជ្ជមានជាច្រើន ហើយបានដោះស្រាយគុណវិបត្តិមួយចំនួននៅក្នុងច្បាប់ក៏ដោយ ក៏លោកនៅតែមានសេចក្តីសោកស្តាយ ដោយវិសោធនកម្មនេះ បានអនុម័តដោយប្រញាប់ប្រញាប់ពេក ដោយពុំមានការពិគ្រោះពិភាក្សាយោបល់ជាសាធារណៈឱ្យបានច្រើន។

៤២- ច្បាប់បោះឆ្នោតដែលបានធ្វើវិសោធនកម្មហើយនេះ ចែងថាសមាជិកគជប ត្រូវដកខ្លួនចេញពីសមាជិកភាពរបស់គណបក្សនយោបាយដែលពួកគេបានចូលរួម។ ប៉ុន្តែ ច្បាប់មិនបានដាក់បញ្ចូលនីតិវិធីនៃការជ្រើសរើសគជបមួយដែលឯករាជ្យពិតប្រាកដ។ ទោះបីជាច្បាប់តម្រូវឱ្យរដ្ឋសភាជាអ្នកអនុម័តយល់ព្រមលើសមាជិកគជបដោយមតិភាគច្រើនដាច់ខាតក៏ដោយ ក៏ច្បាប់ផ្តល់ឱ្យក្រសួងមហាផ្ទៃធ្វើការជ្រើសរើសបេក្ខជនដោយឆន្ទានុសិទ្ធិរបស់ខ្លួនទាំងស្រុង។ ការនេះត្រូវបានប្រើសំរាប់ជ្រើសរើសសមាជិកដែលចូលជាមួយគណបក្សប្រជាជនកម្ពុជា ឬហ៊្វុនស៊ិនប៉ិច។

៤៣- ក្នុងពេលមកបំពេញទស្សនៈកិច្ចរបស់លោកមកកាន់កម្ពុជាក្នុងខែវិច្ឆិកា ឆ្នាំ ២០០២ តំណាងពិសេសបានជួបជាមួយសមាជិកគជបទើបតែងតាំងថ្មី ហើយបានទទួលការធានាថាពួកគេនឹងបំពេញតួនាទីរបស់ខ្លួន ដោយអព្យាក្រិតនិងតម្លាភាព។ ផ្ទុយនឹងសេចក្តីថ្លែងជាសាធារណៈដែលមានកិរិត ដែលបាន ធ្វើឡើងមុនពេលអនុម័តវិសោធនកម្មលើច្បាប់ស្តីការបោះឆ្នោត គជប បានឱ្យមានផ្តួចផ្តើមគំនិតដ៏សំខាន់ ដោយធ្វើការចែកជាសាធារណៈ នូវសេចក្តីព្រាងបទបញ្ជានៃការបោះឆ្នោត ដើម្បីឱ្យជួយផ្តល់មតិ។ អង្គការធានាសំរាប់តាមដាន ត្រួតពិនិត្យការបោះឆ្នោត និងគណបក្សនយោបាយ បានឆ្លៀតប្រើឱកាសដ៏ល្អនេះ។

៤៤- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានប្រគល់ជូនគជបនូវការទទួលខុសត្រូវចំពោះការធានាឱ្យគណបក្សនយោបាយ អាចប្រើប្រាស់ដោយស្មើភាពគ្នា នូវប្រព័ន្ធផ្សព្វផ្សាយ ពត៌មានរបស់រដ្ឋ។ ទាក់ទិនទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៨ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ឆ្នាំ២០០២ តំណាងពិសេសបានសំដែងសេចក្តីព្រួយបារម្ភចំពោះការដែលរដ្ឋាភិបាលខកខានមិនបានធានាសេរីភាពក្នុងការសំដែងមតិ និងក្នុងការបើកសិទ្ធិឱ្យប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានដោយត្រឹមត្រូវយុត្តិធម៌ ហើយនិងចំពោះការរាំងរាពីគជប ចំពោះការផ្តួចផ្តើមគំនិតក្នុងការអប់រំអ្នកបោះឆ្នោត និងការផ្សព្វផ្សាយពត៌មានអំពីគណបក្សនយោបាយ។

៤៥- ដោយចាត់ទុកថាសេរីភាពក្នុងការបញ្ចេញមតិ គឺជាសិទ្ធិមនុស្សជាមូលដ្ឋានមួយ និងការបើកសិទ្ធិការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន របស់រដ្ឋដោយត្រឹមត្រូវយុត្តិធម៌ ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាលក្ខខណ្ឌតម្រូវសំរាប់ការបោះឆ្នោតសេរី និងត្រឹមត្រូវនោះ តំណាងពិសេសបានលើកឡើង ដោយសង្កត់ធ្ងន់អំពីសេចក្តីត្រូវការចាំបាច់ឱ្យរាជរដ្ឋាភិបាល និងគជប ត្រូវតែធានាឱ្យក្នុងការបើកសិទ្ធិប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពត៌មានរដ្ឋ ដោយត្រឹមត្រូវយុត្តិធម៌ និងខិតខំជំរុញឱ្យបានខ្លាំងក្នុងការបើកឱ្យប្រើប្រាស់ដូចគ្នានេះ នូវប្រព័ន្ធផ្សព្វផ្សាយពត៌មានដែលមិនមែនជារបស់រដ្ឋ ជាពិសេសប្រព័ន្ធផ្សព្វផ្សាយពត៌មានអេឡិចត្រូនិក។

៤៦- តាមរយៈច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គជបមានសិទ្ធិអំណាចធំធេងក្នុងការធ្វើការផាកពិន័យ និងការដាក់ទ័ណ្ឌកម្មផ្សេងទៀត ចំពោះអំពើទាំងឡាយដូចជាការលួចបន្លំសន្លឹកឆ្នោតការទិញសន្លឹកឆ្នោត ការធ្វើឱ្យមានការរអាក់រអួលដល់ការបោះឆ្នោត និងកិច្ចដំណើរការរាប់សន្លឹកឆ្នោតនិងការប្រើនិងការអុជអាលឱ្យមានអំពើហឹង្សា និងការគំរាមកំហែងដល់អ្នកបោះឆ្នោត និងបេក្ខជន។ ទោះបីជាអំណាចដូចគ្នានេះត្រូវបាន ផ្តល់ឱ្យគជបសំរាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់កាលពីខែកុម្ភៈ ឆ្នាំ២០០២ ក៏ដោយ ហើយករណីការរំលោភបំពានជាច្រើនករណី លើកជូនគជបជ្រាបក៏នៅតែពុំមានការចាត់ឱ្យដាក់ទ័ណ្ឌកម្មណាមួយទេ។ ទាក់ទិនទៅនឹងការបោះឆ្នោតនាពេលខាងមុខនេះតំណាងពិសេសសូមជំរុញដល់គជប ក៏ដូចជាតុលាការកម្ពុជា ឱ្យប្រើប្រាស់នូវភារៈកិច្ចស្របច្បាប់របស់ខ្លួនដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ប្រឆាំងបុគ្គលទាំងឡាយណា ដែលទទួលខុសត្រូវចំពោះអំពើហឹង្សាការបំភិតបំភ័យ និងការជ្រៀតជ្រែកផ្សេងទៀត នៅក្នុងការប្រើប្រាស់ដោយសេរីនូវសិទ្ធិក្នុងការបោះឆ្នោត ឬកិច្ចដំណើរការបោះឆ្នោតដោយត្រឹមត្រូវ។

៤៧- រហូតមកទល់ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០២ តំណាងពិសេសបានជ្រាបថា មានចំនួន១០ក្នុងក្នុងចំណោមករណី១៧រកាត់ឱ្យជាប់ទោសក្នុងរឿងឃាតកម្ម ទាក់ទិននឹងការបោះឆ្នោតនិងការស្លាប់ ដែលគួរឱ្យសង្ស័យនិងបាននាំខ្លួនជនសង្ស័យទៅកាន់តុលាការ តំណាងពិសេសមានព្រួយបារម្ភថា កិច្ចដំណើរការរបស់តុលាការតែងតែមានគុណវិបត្តិធ្ងន់ធ្ងរជារឿយៗ។ ក្នុងករណីខ្លះ ជនសង្ស័យសំខាន់បានអវត្តមានក្នុងពេលសវនាការ ហើយក្នុងករណីខ្លះ ទៀតតុលាការបានធ្វើការសំរេចថាត្រូវមានទោស ដោយផ្អែកលើមូលដ្ឋានភស្តុតាងតែបន្តិចបន្តួចប៉ុណ្ណោះ។

៤៨- ចាប់តាំងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់កាលពីខែកុម្ភៈ ឆ្នាំ២០០២ រហូតដល់ខែវិច្ឆិកា ឆ្នាំ២០០២ ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា បានធ្វើការស្រាវជ្រាវករណីចំនួន៨ អំពីការសម្លាប់ទាក់ទិននឹងការបោះឆ្នោត។ ក្នុងនេះមានករណីចំនួន៤នៃករណីទាំងនេះ ជនរងគ្រោះ៤នាក់មានជាប់ពាក់ព័ន្ធនឹងគណបក្សសមរង្ស៊ី ៣ករណីមានជាប់ពាក់ព័ន្ធជាមួយគណបក្សហ្វ៊ុនស៊ិនប៉ិច និងមួយករណីទៀតជាកូនស្រីអាយុ១៩ឆ្នាំមានផ្ទៃពោះរបស់ជនរងគ្រោះមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច។

## ង- បញ្ហាដីធ្លី

៤៩- ការដណ្តើមយកដី និងការកើនឡើងនៃអ្នកអត់មានដីក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ ស្ថិតនៅជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរ ដល់សិទ្ធិប្រជាពលរដ្ឋ ក្នុងការទទួលបាននូវកិត្តិយសជីវភាពរស់នៅត្រឹមត្រូវ។ ការអនុវត្តនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សម្បទានព្រៃឈើ ការនេសាទ កសិកម្ម និងប្រភេទផ្សេងទៀតដោយទ្រង់ទ្រាយធំ ដល់ក្រុមហ៊ុនឯកជន បានរួមចំណែកដល់បញ្ហាទទួលបានដីធ្លីរបស់ប្រជាពលរដ្ឋជាទូទៅ។

៥០- ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៩០មក កិច្ចព្រមព្រៀងត្រូវបានធ្វើឡើងរវាងរាជរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនស្តីពីការបង្កើតដីសម្បទានដីចំនួន៤០កន្លែងយ៉ាងតិច សំរាប់ទិសដៅកសិកម្ម ដោយគ្របដណ្តប់ទៅលើផ្ទៃដីជាង៨០០០០០ហិកតា។ សម្បទានទាំងនេះត្រូវបានផ្តល់ជូនរូបវន្តបុគ្គល និងនីតិបុគ្គលនូវទ្រព្យសម្បត្តិឯកជនរបស់រដ្ឋកាប់ឆ្ការសំរាប់ធ្វើអាជីវកម្មឧស្សាហកម្មកសិកម្ម។ ក្នុងរយៈពេលនៃ

សម្បទាននេះ ផ្អែកតាមច្បាប់ភូមិបាលថ្មីដែលទើបបានអនុម័តនៅក្នុងឆ្នាំ២០០១ អាចមានរយៈពេល៩៩ឆ្នាំ។ សម្បទានិកមានសិទ្ធិដូចជាម្ចាស់កម្មសិទ្ធិ លើកលែងតែថាដីកាន់កាប់នេះមិនអាចលក់បានប៉ុណ្ណោះ។ ចំពោះតំបន់ភាគច្រើន ដែលបច្ចុប្បន្នជាសម្បទានកសិកម្ម សម្បទានិកបានកាន់កាប់ដីដោយពុំបានបង់ថ្លៃឈ្នួលឱ្យរដ្ឋទេ។

៥១- បច្ចុប្បន្ន ដីសម្បទានសំរាប់កសិកម្មដ៏ធំជាងគេបង្អស់នៃប្រទេសកម្ពុជា មានទំហំជាង៣០០ ០០០ ហិកតា ដែលស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង និងពោធិសាត់។ តំបន់នេះកាន់កាប់ដោយក្រុមហ៊ុនភាម៉ិច ចំកាត់ដែលត្រួតត្រាបន្ថែមពីលើនេះផ្ទៃដីប្រមាណ៧០០០០០ហិកតា ថែមទៀតជាព្រៃសម្បទាន និងសម្បទានប្រភេទផ្សេងទៀត។ តំណាងពិសេសមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ដោយដីសម្បទាននេះនិងដីសម្បទានសិកម្មដទៃទៀត គឺជាការគំរាមកំហែងដោយផ្ទាល់ ទៅលើប្រជាពលរដ្ឋរាប់ពាន់នាក់ ដែលរស់ពឹងផ្អែកលើដីទាំងនេះ ដើម្បីធានាជីវភាពរស់នៅជាមូលដ្ឋានរបស់ពួកគេ។ ក្នុងពេលបំពេញទស្សនៈកិច្ចលើកទី៧របស់លោកមកកាន់ប្រទេសកម្ពុជា តំណាងពិសេសបានអញ្ជើញទៅទស្សនាស្រុកឱរ៉ាល់ និងភ្នំស្រួច ក្នុងខេត្តកំពង់ស្ពឺ ដែលនៅ ទីនោះក្រុមហ៊ុខាំបូឌាហានីងគ្រុប ត្រូវបានផ្តល់ដីសម្បទានចំនួន២១២៥០ហិកតា សំរាប់រយៈពេល៧០ឆ្នាំ ក្នុងទិសដៅដាំធញ្ញជាតិ និងការចិញ្ចឹមសត្វ។ នៅទីនោះតំណាងពិសេសបានទទួលរបាយការណ៍មកពីក្រុមហ៊ុនថា បានប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ដែលគំរាមកំហែងដល់មនុស្ស និងសត្វនៅទីនោះ។

៥២- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសម្បទានរវាងក្រុមហ៊ុនជាមួយរាជរដ្ឋាភិបាល ធ្វើតាំងពីឆ្នាំ១៩៩៨ម្លេះ ក្រុមហ៊ុនមិនទាន់បានចាប់ផ្តើមធ្វើអ្វីនៅលើដីសម្បទានទាំងនេះនៅឡើយទេ មកទល់ខែមិថុនាឆ្នាំ២០០២។ រហូតមកទល់ពេលនេះ ក្រុមហ៊ុនគ្រាន់តែបានរំលំដោយខុសច្បាប់នូវដើមឈើ អស់ជាច្រើនពាន់ដើម ដាំដើមល្ហុងខ្មែចំរាញ់យកប្រេងបាន៥ទៅ៦ហិកតា សាងសង់ផ្ទះបានមួយចំនួន តម្លើងរោងចក្រអារឈើ និងកែលំអផ្លូវចូលទៅកាន់តំបន់សម្បទាន បានមួយផ្នែកប៉ុណ្ណោះ។

៥៣- នៅតំបន់សម្បទានមានប្រជាពលរដ្ឋរស់នៅជាង៨៥០០នាក់ ដែលរាយប៉ាយនៅតាមភូមិចំនួនជាង២៦។ នៅក្នុងទស្សវត្តន៍ឆ្នាំ១៩៨០ នៅពេលដែលពួកខ្មែរក្រហមត្រួតត្រាខ្លះៗលើតំបន់នេះ គ្រួសារភាគច្រើននៃប្រជាពលរដ្ឋផ្លាស់មករស់នៅតាមដងផ្លូវជាតិលេខ៤ ដែលតភ្ជាប់ពីទីក្រុងភ្នំពេញ ទៅក្រុងព្រះសីហនុ ដែលស្ថិនៅភាគនិរតីនៃប្រទេសកម្ពុជា។ បន្ទាប់ពីការចុះចូល ដ៏រីករាលដាលនៃខ្មែរក្រហម

កាលពីឆ្នាំ១៩៩៦ រដ្ឋាភិបាលបានលើកទឹកចិត្តប្រជាពលរដ្ឋផ្លាស់ប្តូរទីកន្លែងនៅ ក្នុងស្រុកឱ្យវិលត្រឡប់ទៅកាន់ភូមិរបស់ពួកគេវិញ។ នៅក្នុងឆ្នាំ១៩៩៧ និង១៩៩៨ ប្រជាពលរដ្ឋជាច្រើនបាន វិលត្រឡប់ទៅវិញ។

៩៤- បន្ទាប់ពីមានគ្រោះរាំងស្ងួត៣ឆ្នាំមក ឥឡូវនេះប្រជាពលរដ្ឋកំពុងតស៊ូរស់នៅក្នុងតំបន់នេះ។ ស្ថានភាពរបស់ពួកគេបានចុះដុនដាបថែមទៀត ដោយមានការណែនាំពីមន្ត្រីខាងពង្រឹងអនុវត្តច្បាប់ និងតំណាងក្រុមហ៊ុន ឱ្យឈប់ប្រើដីធ្វើកសិកម្ម និងព្រៃឈើ ដែលស្ថិតនៅក្នុងតំបន់សម្បទាន។ ធម្មតាដីនេះត្រូវបានប្រជាពលរដ្ឋប្រើដើម្បីធ្វើស្រែ និងដាំបន្លែ ចិញ្ចឹមគោក្របី និងធ្វើឱស និងធ្យូង។ មានគ្រួសារខ្លះត្រូវបញ្ជាឱ្យចុះចេញពីផ្ទះថែមទៀត។ ប្រជាពលរដ្ឋនៅក្នុងតំបន់នេះ ក៏ដូចជាអាជ្ញាធរភូមិឃុំ បានលើកឡើងអំពីសេចក្តីព្រួយបារម្ភរបស់ពួកគេ ជូនថ្នាក់ខេត្ត និងថ្នាក់ជាតិនៃរដ្ឋាភិបាល។ ជាការច្បាស់ណាស់ដែលថា បើសិនជាក្រុម ហ៊ុនត្រូវបានអនុញ្ញាតឱ្យអនុវត្តដោយកម្លាំងនូវការណែនាំនេះ នោះផលប៉ះពាល់ដល់ប្រជាពលរដ្ឋនឹងមាន សភាពធ្ងន់ធ្ងរណាស់។

៩៥- ដើម្បីរក្សាការជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ លើដីសម្បទានកសិកម្ម តំណាងពិសេសបានស្នើឱ្យដល់រាជរដ្ឋាភិបាលសូមឱ្យចាត់វិធានការពិនិត្យឡើងវិញ នូវកិច្ចសន្យាសម្បទានកសិកម្មទាំងអស់ និងការអនុវត្តកិច្ចសន្យាទាំងនោះ ហើយសូមឱ្យពិនិត្យពិចារណាប្រើសិទ្ធិស្របច្បាប់របស់ខ្លួន ក្នុងការដកហូតមកវិញ នៅពេលណាដែលក្រុមហ៊ុនមិនគោរពតាមបទបញ្ញត្តិនៃច្បាប់កម្ពុជា និងលក្ខខណ្ឌតម្រូវនៃកិច្ចសន្យា។ ក្រុមហ៊ុនខាំបូឌាហានីងគ្រុបចំកាត់ បានរំលោភដោយវិធីផ្សេងៗ ទាំងលើច្បាប់ជាធរមាន និងកិច្ចសន្យារបស់ខ្លួនជាមួយក្រសួងកសិកម្ម រុក្ខា និងនេសាទផង។ ក្រុមហ៊ុនមិនបានចាប់ផ្តើមសកម្មភាពធ្វើផលិតកម្មកសិកម្មរបស់ខ្លួន ក្នុងរយៈពេលដែលបានកំណត់ទេ មិនបាន បង់ថ្លៃឈ្នួលតាមពេលវេលាកំណត់ មិនបានចាត់វិធានការសិក្សាវាយតម្លៃពីផលប៉ះពាល់ដល់បរិដ្ឋានដែលចាំបាច់ដែលត្រូវធ្វើនោះទេ បានធ្វើ សកម្មភាពកាប់ឈើដោយខុសច្បាប់ និងបានដំណើរការរោងចក្រអារឈើ ដោយគ្មានច្បាប់អនុញ្ញាត។

៩៦- ច្បាប់ភូមិបាលចែងជាក្រិត្យក្រមទូទៅថា តំបន់ដីសម្បទានមិនត្រូវមានទំហំលើសពី១0000 ហិកតាទេ ហើយថាសម្បទានដែលមានស្រាប់ ដែលមានទំហំលើសពីការកំរិតនេះ ត្រូវតែកាត់បន្ថយ។ នីតិវិធីសំរាប់ការ កាត់បន្ថយបែបនេះ និងការលើកលែងជាពិសេសត្រូវកំណត់ដោយអនុក្រិត ។

នីតិវិធីក្នុងការផ្តល់ដីសម្បទាន ក៏ត្រូវកំណត់ដោយអនុក្រិត្យដែរ។ បទបញ្ញាប្រតិបត្តិទាំងពីរនេះ នៅមិនទាន់បានអនុម័តនៅឡើយទេ។

៥៧- សម្បទានព្រៃឈើបានគ្រប់ដណ្តប់ លើផ្ទៃក្រឡាជិត៤លានហិកតា នៃផ្ទៃដីប្រទេសកម្ពុជាប្រមាណ១៨លានហិកតា។ នៅពេលជួបពិភាក្សារវាងតំណាងពិសេស និងនាយករដ្ឋមន្ត្រីកាលពីខែវិច្ឆិកា ឆ្នាំ២០០២ នាយករដ្ឋមន្ត្រីបានថ្លែងថា លោកបានត្រៀមលក្ខណៈលុបចោលព្រៃសម្បទានទាំងអស់ បើសិនជាចាំបាច់ ដើម្បីសង្គ្រោះព្រៃដែលនៅសល់។ តាមការសិក្សារបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក ប្រជាពលរដ្ឋជាង២លាន៣សែននាក់ ពឹងផ្អែកដោយផ្ទាល់លើព្រៃឈើសំរាប់ជីវភាពរស់នៅរបស់ពួកគេ។ ដូច្នេះជាការជាក់ស្តែងណាស់សេចក្តីសំរេចណាមួយ ទាក់ទងទៅនឹងការប្រើប្រាស់ព្រៃឈើរបស់កម្ពុជាត្រូវគិតជាគួរយកចិត្តទុកដាក់ជាពិសេស និងដោយប្រុងប្រយ័ត្ន ចំពោះជីវភាពប្រជាពលរដ្ឋរស់នៅក្នុង និងជុំវិញតំបន់សម្បទាន។

៥៨- តាមកម្មវិធីកែទម្រង់ព្រៃឈើដែលកំពុងប្រព្រឹត្តទៅ តម្រូវឱ្យសម្បទានិករៀបចំផែនការថាតើត្រូវចាត់ចែងគ្រប់គ្រងព្រៃឈើយ៉ាងដូចម្តេច ដើម្បីឱ្យមាននិរន្តរភាព ហើយដែលផ្អែកសង្គម និងបរិស្ថានអាចទទួលយកបាន ក្នុងរយៈពេល២៥ឆ្នាំខាងមុខ។ ច្បាប់ព្រៃឈើដែលអនុម័តកាលពីខែកញ្ញា ឆ្នាំ២០០២ តម្រូវឱ្យដាក់ផែនការទាំងនេះ ជូនសាធារណៈជនឱ្យបានដឹង ដើម្បីផ្តល់យោបល់។ ទីប្រឹក្សាអន្តរជាតិ បានប្រមាណថាដើម្បីនឹងធ្វើការពិគ្រោះពិភាក្សាយោបល់ ជាមួយសហគមន៍ឱ្យបានត្រឹមត្រូវ។ ប៉ុន្តែផែនការគ្រប់គ្រងត្រូវបានដាក់ជូនសាធារណៈជនកាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០២ ហើយអវសានវាទសំរាប់ជូនយោលើផែនការទាំងនេះគឺថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០២។ ជាការច្បាស់ណាស់ថា រយៈពេលពិគ្រោះពិភាក្សាយោបល់ដែលមានតែ១៩ថ្ងៃ ដែលក្នុងនោះរួមបញ្ចូលទាំងមានថ្ងៃឈប់សំរាកសំរាប់បុណ្យអុំទូកផងនោះ គឺមិនគ្រប់គ្រាន់ទេ ដើម្បីធានាឱ្យសហគមដែលមានផលប៉ះពាល់ និងអង្គការក្រៅរដ្ឋាភិបាល មានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើការពិនិត្យពិច័្ចយ និងរៀបចំផ្តល់យោបល់ដោយលំអិតលើឯកសារដ៏ល្អិល្អន់នេះទេ។ ជាការដែលគួរឱ្យរំខានដូចគ្នានេះដែរ គឺឧបមាថាបន្ទាប់ពីផែនការនេះត្រូវបានធ្វើជាសាធារណៈជាផ្លូវការហើយនោះ តំណាងសហគមន៏ដែលរស់នៅដោយពឹងផ្អែកលើព្រៃឈើត្រូវបដិសេធមិនព្រមផ្តល់ឱ្យនូវអត្ថបទចម្លងនៃផែនការពីនាយកដ្ឋានរុក្ខា និងប្រម៉ាញ់នៅភ្នំពេញ។ ធនាគារពិភពលោកបាន យល់ព្រមជួយរដ្ឋាភិបាលក្នុងការចែកផ្សាយផែនការនេះ តែខកខានមិនបានធ្វើដោយមូលហេតុដែលអាចទទួលយកបាន។ នៅទីបំផុត កិច្ចការផ្សព្វផ្សាយផែនការគ្រប់គ្រងត្រូវបញ្ចប់

ដោយគ្រាន់តែអង្គការក្រៅ រដ្ឋាភិបាលមួយចំនួនបានធ្វើការចែកផ្សាយដោយមានកំរិត។ តំណាងពិសេសបានមានមតិថា ការទទួលខុសត្រូវក្នុងការធានាឱ្យប្រជាពលរដ្ឋកម្ពុជាអាចមានសម្លេង ត្រឹមត្រូវក្នុងការកំណត់ពីអនាគតផ្ទាល់របស់ពួកគេ គឺពឹងផ្អែកលើរាជរដ្ឋាភិបាល និងលើសហគមន៍ផ្តល់ជំនួយអន្តរជាតិ។

៥៩- កាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០២ នាយប៉ូលីស និងកងរាជអាវុធហត្ថ បានប្រើកម្លាំងខ្លាំងហួសហេតុដើម្បីបំបែកតំណាងសហគមន៍ ដែលរស់នៅដោយពឹងផ្អែកលើព្រៃឈើ ចំនួនប្រមាណ១៥០នាក់ ដែលរង់ចាំនៅខាងក្រៅនាយកដ្ឋានរុក្ខា និងប្រម៉ាញ់ ដែលស្ថិតនៅកណ្តាលក្រុងភ្នំពេញ ដើម្បីនឹងទទួលការឆ្លើយតបទៅនឹងការចូលរួមរបស់នាយកដ្ឋាន ក្នុងសិក្ខាសាលាមួយស្តីពីផែនការគ្រប់គ្រងព្រៃឈើ។ ក្នុងការបំបែកហ្វូងមនុស្សអហឹង្សា មន្ត្រីប្រតិបត្តិច្បាប់បានវាយទាត់ធាក់ និងប្រើដំបងឆក់ខ្សែភ្លើង ទៅលើមនុស្សស្រីប្រុសជាច្រើននាក់។ តំណាងម្នាក់ ឈ្មោះ ហែម សៅ អាយុ២៩ឆ្នាំ ប្រធានភូមិមកពីខេត្តព្រះវិហារបានស្លាប់នៅក្នុងពេលប៉ុន្មានម៉ោងក្រោយមក។ នៅពេលដែលមូលហេតុនៃការស្លាប់រកមិនទាន់ឃើញនៅឡើយ គេបានដឹងច្បាស់ថា ដំបងឆក់ដោយខ្សែភ្លើង គឺមានសក្តានុភាពបណ្តាលឱ្យស្លាប់នេះ ដោយធ្វើឱ្យចលនាសាច់ដុំបេះដូងកន្ត្រាក់ដើរមិនស៊ីសង្វាក់គ្នា។ តំណាងពិសេស ផ្តន្ទាទោសការប្រើកម្លាំងដោយហួសហេតុដោយមន្ត្រីប្រតិបត្តិច្បាប់ និងអំពាវនាវដល់រាជរដ្ឋាភិបាល ឱ្យហាមប្រាមកុំឱ្យប្រើដំបងឆក់ដោយខ្សែភ្លើងដើម្បីបង្ក្រាបលើហ្វូងមនុស្ស។

## ច- បញ្ហាលំនៅដ្ឋាន

៦០- តំណាងពិសេសបានតាមដានបញ្ហាលំនៅដ្ឋាន ដោយផ្តោតជាពិសេសលើការតាំងលំនៅថ្មី។ ទីកន្លែងសំរាប់តាំងលំនៅថ្មី ដូចជាអន្លង់ក្ងានជាដើម ត្រូវបានរើយកទៅដាក់ដោយសារមានអគីភ័យ នៅតំបន់រស់នៅនៃជនក្រីក្រនៅបាសាក់ និងដើមចាន់ ក្នុងទីក្រុងភ្នំពេញ កាលពីខែវិច្ឆិកា ឆ្នាំ២០០១។ វិនិយោគឯកជន និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ក៏ធ្វើឱ្យការផ្លាស់ប្តូរការតាំងទីលំនៅដែរ។

៦១- ការតាំងលំនៅថ្មីត្រូវផ្អែកលើគោលនយោបាយសមស្រប ដែលត្រូវផ្តល់ជំរកឱ្យបានត្រឹមត្រូវ និងកំរិតជីវភាពរស់នៅសមរម្យ។ ក្នុងគោលនយោបាយនេះត្រូវគិតគូរដោះស្រាយពីបញ្ហាសន្តិសុខ មានទឹកទទួលទាន មានអនាម័យកន្លែងសំរាប់ព្យាបាលសុខភាព និងអប់រំ ក៏ដូចជាការអាចរកងារធ្វើ និងអាចមានលទ្ធភាពរកចំណូលបាន។ កាលពីខែសីហា ឆ្នំ២០០១ អង្គការក្រៅរដ្ឋាភិបាល ដោយមានការ

ចូលរួមពីខាងរាជធានីភ្នំពេញផង បានរៀបចំរងក្រុងជាគោលការណ៍ណែនាំមួយ សំរាប់ការតាំងលំនៅថ្មី សំរាប់ទីក្រុងភ្នំពេញ។ តែជាអកុសលអាជ្ញាធរមាននិន្នាការធ្វើមិនដឹងមិនឮចំពោះ គោលការណែនាំនេះ ទោះបីជាគេបានផ្តល់ការណែនាំយ៉ាងល្អត្រឹមត្រូវអំពីថា តើត្រូវធ្វើអ្វីខ្លះមុនពេល និងក្រោយការតាំងលំនៅរបស់សហគមន៍ និងអំពីគោលដៅដើម្បីកំរិតផលប៉ះពាល់អវិជ្ជមាន ទៅលើសហគមន៍ដែលបានយល់ព្រមទៅតាំងលំនៅថ្មី។

៦២- នៅពេលជួបសវនាការជាមួយព្រះមហាក្សត្រ ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ កាលពីខែមិថុនា ឆ្នាំ២០០២ តំណាងពិសេសបានលើកថ្វាយនូវបញ្ហាចែកជំនួយដល់គ្រួសារដែលគ្មានដីធ្លីនៅអន្លង់ក្ងាន។ កាលពីខែកក្កដា ឆ្នាំ២០០២ ព្រះបរមរាជវាំងបានផ្តល់ជំនួយ តែឱ្យចំពោះតែគ្រួសារដែលមានប័ណ្ណដើម្បីទទួលដីប៉ុណ្ណោះ ហើយជំនួយនេះមិនបានទៅដល់ការត្រូវការចាំបាច់នោះទេ។ នៅពេលជួបសវនាការជាមួយព្រះមហាក្សត្រកាលពីខែវិច្ឆិកា ឆ្នាំ២០០២ តំណាងពិសេសត្រូវបានលើកទឹកចិត្តដោយព្រះមហាក្សត្រ នៅតែមានការព្រួយបារម្ភតទៅទៀត និងការប្តេជ្ញាចិត្តចំពោះគ្រួសារដែលមិនត្រូវបានផ្តល់ដីជូន។ តំណាងពិសេសក៏បានលើក ឡើងអំពីសេចក្តីព្រួយបារម្ភរបស់លោកនៅពេលជួបប្រជុំជាមួយលោកអភិបាលរាជធានីភ្នំពេញ ជា សុផារ៉ា ហើយបានទាញអារម្មណ៍របស់លោកអំពីការដែលគ្រួសារចំនួនជាង៨០០គ្រួ ដែលមិនបានទទួលដីដូចដែលបានសន្យាកាលពីពេលមុន។

## ឆ- ការជួញដូរមនុស្ស

៦៣- តំណាងពិសេសបានយកចិត្តទុកដាក់ជាពិសេសលើបញ្ហាជួញដូរមនុស្ស ដែលជាការព្រួយបារម្ភដ៏ធំមួយចំពោះកម្ពុជាជាប្រទេសប្រភពដើម ជាកន្លែងឆ្លងកាត់ និងជាគោលដៅនៃការជួញដូរបែបនេះ។ ភាពក្រីក្រដោយតំបន់ ការខ្វះខាតខាងការអប់រំ អស្ថេរភាពនៃប្រវត្តិរបស់គ្រួសារ អំពើពុករលួយ និងការខកខានមិនបានអនុវត្តច្បាប់ សុទ្ធតែជាកត្តារួមចំណែក។

៦៤- ការជួញដូរជាសំខាន់កើតមាននៅក្នុងប្រទេស ជាពិសេសពីតំបន់ជនបទមកកាន់ទីក្រុង តំបន់ទេសចរណ៍ និងតំបន់ព្រំដែន ។ អ្នកដែលមានផលប៉ះពាល់ជាសំខាន់គឺស្ត្រី និងក្មេង ដែលភាគច្រើនត្រូវបានបង្ខំ ឬកៀបសង្កត់ឱ្យធ្វើជាពេស្យាចារ ជួល ឬលក់ ជាសំខាន់ដោយឪពុកម្តាយ និងបងប្អូន ឬត្រូវចាប់ពង្រត់។ ការជួញដូរមនុស្សក៏បានកើតមានឡើងក្នុងទិសដៅផ្សេងពីអាជីវកម្មផ្លូវភេទ ដូចជា

ការសុំទាន ឬការយកទៅឱ្យធ្វើការ។ ការជួញដូរឆ្លងកាត់ព្រំដែនកើតមានជាទូទៅ និងរួមទាំងការជួញដូរទៅកាន់ប្រទេសផ្សេង និងទាំងពីប្រទេសផ្សេងមកកាន់កម្ពុជា ដោយជ្រើសរើសជាពិសេសនៅតាមខេត្តស្ថិតនៅតាមព្រំដែន។ ការជួញដូរមនុស្សសំរាប់ទិសដៅធ្វើជាកូនចិញ្ចឹម ក៏ជាបញ្ហា នៃកង្វល់ដែលចេះតែកើនឡើងដែរ។

៦៥- សេចក្តីព្រាងច្បាប់ថ្មីមួយស្តីពីការលប់បំបាត់ការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទដើម្បីជំនួសច្បាប់ឆ្នាំ១៩៩៦ កំពុងមានការរីកចំរើនទៅមុខ។ ជាការសំខាន់ណាស់ដែលច្បាប់នេះ បានចែងអំពីការយកចិត្តទុកដាក់និងការការពារ ជាពិសេសចំពោះជនរងគ្រោះ ដូចដែលមានចែង និងរៀបរាប់នៅក្នុងគោលការណ៍ជាអនុសាសន៍ និងការណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស (E/2002/68/Add.1)។ ជនរងគ្រោះមិនត្រូវចាត់ទុកថា ជាអ្នករំលោភច្បាប់អន្តោប្រវេសន៏ដូចដែលតែងតែកើតមាននៅក្នុងប្រទេសកម្ពុជាទេ។ អតីតឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស បានចេញសេចក្តីអំពាវនាវជាពិសេសចំពោះបញ្ហានេះ នៅចំពោះមុខរដ្ឋសភា កាលពីខែសីហា ឆ្នាំ២០០២។ ច្បាប់ថ្មីក៏ត្រូវផ្តល់វិធានការខ្លាំងក្លាដើម្បីផ្តន្ទាទោសជនដែលត្រូវទទួលខុសត្រូវដែរ។

៦៦- តំណាងពិសេសមានសេចក្តីព្រួយបារម្ភ ចំពោះការខកខានរបស់តុលាការមិនបានពង្រឹងច្បាប់។ ការតវ៉ាទាមទាររបស់ជនរងគ្រោះតែងតែត្រូវបដិសេធ ឬចាត់ថាពួកគេជាឧក្រិដ្ឋជនជាជាងទទួលបានការគាំទ្រ។ អង្គការក្រៅរដ្ឋាភិបាលមួយបានរាយការណ៍ថា ក្នុងឆ្នាំ២០០១ខ្លួនបានទទួលដោះស្រាយករណីចំនួនប្រមាណ៩៤ភាគរយនៃករណីជួញដូរមនុស្ស ដែលតុលាការខកខានមិនបានដាក់ទោសដល់អ្នកទទួលខុសត្រូវចំពោះករណីទាំងនេះទេ។ ជាទូទៅ បើសិនជាមានការដាក់ទោស តែងតែធ្វើចំពោះតែមនុស្សនៅថ្នាក់ទាបបំផុត។ នៃបណ្តាញជួញដូរមនុស្ស ឬសមាជិកគ្រួសារដែលបានទទួលលុយពីកូនរបស់ពួកគេប៉ុណ្ណោះ។ កាលពីខែមិថុនា ឆ្នាំ២០០២ នគរបាលបានវាយឆ្មក់ ហើយបានចូលជួយ "សង្គ្រោះ" ក្មេងស្រីវៀតបានមួយក្រុមចំនួន១៤នាក់ ពីបនស្រីពេស្យាមួយនៅស្វាយប៉ាក។ មិនទាន់មានជនណាម្នាក់ត្រូវបានយកមកកាត់ទោសពីបទជួញដូរ ឬអ្នកនាំស្រីទាំងនេះមកទេ តែក្រោយមកជនរងគ្រោះភាគច្រើនបែរជាត្រូវបានផ្តន្ទាទោសដោយមានទោសជាប់ពន្ធនាគារ ដោយត្រូវចោទក្រកាន់ថា ជាអន្តោប្រវេសន៏ខុសច្បាប់ ដូចមនុស្សពេញវ័យទៅវិញ។

៦៧- នៅក្នុងសវនាការករណីនារីទាំងនេះ ដែលត្រូវចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់ នៅតុលាការរាជធានីភ្នំពេញ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ អនីតិជន៣នាក់ ត្រូវបានលើកលែងការចោទប្រកាន់ ដោយមានឯកសារបញ្ជាក់ពីឃុំស្វាយប៉ាក ថាគេកើតនៅប្រទេសកម្ពុជា និងម្នាក់ទៀតថាខ្លួនបានមករស់នៅប្រទេសកម្ពុជាតាំងពីខ្លួនមានអាយុ១ឆ្នាំម្លេះ។ នារី៦នាក់ដែលត្រូវទទួលស្គាល់ជាផ្លូវការថា មានអាយុ១៨ឆ្នាំ ត្រូវបានកាត់ឱ្យជាប់ពន្ធនាគារចំនួន២ខែ ជាមួយនារីម្នាក់ទៀតដែមានអាយុ១៦ឆ្នាំ ជាផ្លូវការ។ រីឯនារី៣ដែលជាផ្លូវការមានអាយុពី១៩និង២២ឆ្នាំ ត្រូវកាត់ឱ្យជាប់ពន្ធនាគារចំនួន៣ខែ។ នារីទាំង១០នាក់នេះ ត្រូវបានតុលាការបង្គាប់ឱ្យបញ្ជូនត្រឡប់ទៅប្រទេសវៀតណាមវិញក្រោយពេលចេញពីពន្ធនាគារ។ បន្ទាប់ពីត្រូវបំពេញទោស នៅក្នុងពន្ធនាគារចប់សព្វគ្រប់ហើយមកពួកគេត្រូវបានបញ្ជូនទៅកាន់ជំរុំរបស់នាយកដ្ឋានអន្តោប្រវេសន៍ ដែលស្ថិតនៅជិតអាកាសយានដ្ឋានពោធិចិនតុង។ ប៉ុន្តែនៅពេលអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធទាក់ទងជាមួយមជ្ឈមណ្ឌលនេះ ដើម្បីសំរួលការទទួលយកនារីទាំងនេះទៅកាន់ជុំរកនៅទីក្រុងហូជីមិញនោះ ពួកគេត្រូវបានគេប្រាប់ថា គេមិនដឹងថានារីទាំងនេះស្ថិតនៅទីណាទេ។ នេះធ្វើឱ្យមានការបារម្ភថា នារីទាំងនេះអាចត្រូវបានដោះឱ្យរួចខ្លួនជាថ្នូរនឹងការឱ្យលុយទៅមន្ត្រីនាយកដ្ឋានអន្តោប្រវេស្តន៍។ ករណីនេះឆ្លុះបញ្ចាំងឱ្យឃើញការខ្វះខាតជាខ្សែសង្វាក់ នៃប្រព័ន្ធតុលាការក្នុងការគោរពសិទ្ធិរបស់ជនរងគ្រោះ និងចាប់អ្នកប្រព្រឹត្តល្មើសឱ្យទទួលខុសត្រូវទទួលនូវកំហុសខ្លួនប្រព្រឹត្ត ។

៦៨- តំណាងពិសេសមានការព្រួយបារម្ភថា ធនធានថវិកាដ៏តិចតួចពេកផ្តល់ឱ្យក្រសួងសង្គមកិច្ច ដែលទទួលខុសត្រូវក្នុងការផ្តល់ និងការសំរបសំរួលសេវាសង្គមកិច្ចដល់អ្នករងគ្រោះពីការជួញដូរមនុស្ស។ បច្ចុប្បន្ននេះ សេវាកម្មស្ទើរតែទាំងស្រុង គឺបានផ្តល់ឱ្យដោយអង្គការក្រៅរដ្ឋាភិបាលនានា។

៦៩- តំណាងពិសេសសូមសំដែងការស្វាគមន៍ ចំពោះការផ្តល់សច្ចាប័ណ្ណរបស់ប្រទេសកម្ពុជា កាលពីខែឧសភា ឆ្នាំ២០០២ លើពិធីសាស្ត្រគ្រចិត្តនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ស្តីពីការលក់ដូរកុមារពេស្យាកម្មកុមារ និងការថតរូបអាសអាភាសនៃកុមារ។

## ជ- អ្នកស្វែងរកសិទ្ធិជ្រកកោន

៧០- មនុស្សមួយចំនួននៃក្រុមជនជាតិភាគតិចនៅខ្ពង់រាបវៀតណាមកណ្តាល បានស្វែងរកការជ្រកកោននៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីការបិទនិងបំផ្លាញជំរុំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួននៅខេត្តជាប់ព្រំដែនមណ្ឌលគីរីមក។ ប៉ុន្តែតំណាងពិសេសបានទទួលរបាយការណ៍មិនទាន់បានបញ្ជាក់ថាពិតមួយចំនួនពីប្រភពដែលគួរឱ្យជឿបានថា សមាជិកជនជាតិភ្នំជាច្រើននាក់ជាអ្នកស្វែងរកសិទ្ធិជ្រកកោន បានលាក់ខ្លួននៅតាមណ្តោយព្រំដែនកម្ពុជា-វៀតណាមទាំងសងខាង។ លោកក៏ត្រូវបានឱ្យដឹងថាពួកអ្នកស្វែងរកសិទ្ធិជ្រកកោនជាជនជាតិភ្នំមកពីប្រទេសវៀតណាម ត្រូវបានបង្ខំចាប់បញ្ជូនទៅកាន់ប្រទេសវៀតណាមវិញ និងថាមានការបំភិតបំភ័យ និងការគំរាមកំហែង ទាំងពីសំណាក់អជ្ញាធរកម្ពុជា និងវៀតណាមទៅលើអ្នកទាំងឡាយ ដែលកាលពីពេលមុនធ្លាប់បានជួយដល់ពួកអ្នកស្វែងរកការជ្រកកោននេះ។ រដ្ឋាភិបាលបានបដិសេធមិនឱ្យឧត្តមស្នងការអង្គការសហប្រជាជាតិ សំរាប់ជនភៀសខ្លួនចូលទៅកាន់តំបន់នេះដោយសេរីទេ ដែលនេះមានន័យថាពួកអ្នកស្វែងរកសិទ្ធិជ្រកកោនត្រូវបានទប់ស្កាត់ដោយជាក់ស្តែង មិនឱ្យឧត្តមស្នងការអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន ពិនិត្យលើពាក្យសុំទាមទារសិទ្ធិជ្រកកោនរបស់ពួកគេទេ។

៧១- ពួកអ្នកស្វែងរកសិទ្ធិជ្រកកោនដទៃទៀត និងជនភៀសខ្លួន ក៏ត្រូវបញ្ជូនត្រឡប់ទៅវិញដែរ។ នៅដើមខែសីហា ឆ្នាំ២០០២ ជនជាតិចិន និងសាសនិកហ្វាលុងគុង២នាក់ លោកស្រីចាង ស៊ុនយី និងលោកលី គួជុន ត្រូវបានចាប់ខ្លួននៅក្នុងផ្ទះរបស់ពួកគេ បញ្ជូនទៅស្រុកចិនវិញ។ អ្នកទាំង២នាក់នេះសុទ្ធតែកាន់លិខិត "មនុស្សដែលមានគួរឱ្យព្រួយបារម្ភ" របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន។ បន្ទាប់ពីបណ្តេញពួកគេចេញ មនុស្សទាំង២នាក់នេះ សុទ្ធតែត្រូវបានយកទៅដាក់ក្នុងមន្ទីរឃុំឃាំងដែលមានការហាមឃាត់មិនឱ្យចូលទាក់ទង នៅមណ្ឌលឃុំឃាំងឆាងសានៃខេត្តហ៊ូណាន។

៧២- ប្រទេសកម្ពុជាជាភាគីមួយនៃអនុសញ្ញាទាក់ទិននឹងឋានៈជនភៀសខ្លួន ដែលតម្រូវឱ្យស្ថិតនៅក្រោមច្បាប់អន្តរជាតិមិនឱ្យបញ្ជូនត្រឡប់ទៅវិញ មនុស្សណាម្នាក់ទៅកាន់ប្រទេសមួយ ដែលខ្លួនគេ និងសេរីភាពរបស់គេអាចរងការគំរាមកំហែងដោយសារពូជសាសន៍ សាសនា សញ្ជាតិ សមាជិកនៃក្រុមសង្គម ឬនយោបាយណាមួយ។

## I- កាតព្វកិច្ចធ្វើរបាយការណ៍

៧៣- ក្នុងឋានៈជារដ្ឋភាគីនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ ៧ ប្រទេសកម្ពុជាត្រូវបំពេញកាតព្វកិច្ចធ្វើរបាយការណ៍ដ៏សំខាន់ ។ តំណាងពិសេសសំដែងស្វាគមន៍ចំពោះការដាក់ជូនកាលពីពេលថ្មីៗ នេះនូវរបាយការណ៍លើកដំបូងរបស់ខ្លួនជូនគណៈកម្មការប្រឆាំងទារុណកម្ម។ ប៉ុន្តែប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងការយឺតយ៉ាវយ៉ាងខ្លាំង ក្នុងការបំពេញភារកិច្ចធ្វើរបាយការណ៍របស់ខ្លួន។ តំណាងពិសេសសង្ឃឹមថា រដ្ឋាភិបាលនឹងបញ្ចប់ក្នុងពេលដ៏ឆាប់ៗនេះនូវរបាយការណ៍លើកដំបូង ស្ដីពីការអនុវត្តអនុសញ្ញាស្ដីពីការលុបបំបាត់គ្រប់រូបភាព នៃការរើសអើងប្រឆាំងនារីភេទ និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក៏ដូចជារបាយការណ៍តាមការកំណត់ ស្របតាមអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់គ្រប់រូបភាពនៃការប្រកាន់ពូជសាសន៍។ រដ្ឋាភិបាលក៏គួរចាប់ផ្ដើមធ្វើផងដែរនូវរបាយការណ៍ដែលយឺតយ៉ាវហួសកំណត់នៃការធ្វើរបាយការណ៍តាមកាលកំណត់ ស្ដីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

៧៤- នៅក្នុងពេលបំពេញទស្សនៈកិច្ច តំណាងពិសេសបានទទួលរបាយការណ៍ស្របគ្នាមួយដែលរៀបចំឡើងដោយគណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាល សំរាប់តាមដានអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលពិពណ៌នារៀបរាប់ឱ្យឃើញ អំពីស្ថានភាពដែលបានស្រាវជ្រាវកត់ត្រាឯកសារបានយ៉ាងល្អមួយ លើកឡើងអំពីឧបសគ្គគួរឱ្យកត់សំគាល់ ដែលប្រទេសកម្ពុជាកំពុងប្រឈមមុខក្នុងការអនុវត្តន៍កតិកាសញ្ញា និងផ្ដល់នូវអនុសាសន៍ជាជំនួយ។ តំណាងពិសេសសំដែងការកោតសរសើរដល់របាយការណ៍នេះចំពោះរដ្ឋាភិបាលហើយស្នើថា រដ្ឋាភិបាលគួរពិចារណាបញ្ចូលអនុសាសន៍នៃរបាយការណ៍នេះទៅក្នុងផែនការកែទម្រង់ និងអភិវឌ្ឍន៍។ លោកក៏បានលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ឱ្យបន្តការពិភាក្សាជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល ក្នុងកិច្ចខិតខំដើម្បីធ្វើច្បាប់កម្ពុជា និងការអនុវត្តឱ្យស្របទៅនឹងបទបញ្ញត្តិនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗ។

## III- សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

៧៥- តំណាងពិសេសបានជំរុញប្រទេសផ្ដល់ជំនួយទាំងឡាយ និងរាជរដ្ឋាភិបាលឱ្យអនុម័តគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដើម្បីរក្សាការពារ និងយកចិត្តទុកដាក់ឱ្យពេញលេញពីសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋកម្ពុជា អនុម័តយកវិធីសាស្ត្រក្នុងការធ្វើឱ្យមានការចូលរួម

និងផ្តល់សម្លេងដល់អ្នកក្រីក្រ ។ វិធីសាស្រ្តដែលផ្អែកលើសិទ្ធិដើម្បីអភិវឌ្ឍន៍ គឺជានយោបាយដែលបង្ហាញយ៉ាងច្បាស់អំពីការឈរលើបទដ្ឋានសិទ្ធិមនុស្ស និងតម្លៃដោយជាក់លាក់ ។ តំណាងពិសេសសង្កត់ធ្ងន់អំពីសេចក្តីត្រូវការឱ្យផ្តោតទៅលើកំណើនសេដ្ឋកិច្ច ដើម្បីគោលដៅផ្តល់អត្ថប្រយោជន៍ ជូនប្រជាពលរដ្ឋទាំងមូលជាពិសេសអ្នកក្រីក្រ ។ កន្លងមកនេះអាទិភាពខ្ពស់ជាងគេ គឺត្រូវបានផ្តល់ទៅឱ្យកំណើនសេដ្ឋកិច្ចនៃផ្នែកឯកជន ដោយពុំបានយកចិត្តទុកដាក់គ្រប់គ្រាន់ ទៅលើការគោរពសិទ្ធិមនុស្ស និងសមធម៌ឡើយ ។ ប្រទេសកម្ពុជាត្រូវការអភិវឌ្ឍន៍មនុស្ស និងប្រកបដោយនិរន្តភាព ការអភិវឌ្ឍន៍មនុស្សដែលមានន័យថាមនុស្សគឺជា "ប្រធានពទស្នូលនៃការអភិវឌ្ឍន៍" ហើយនិងការអភិវឌ្ឍន៍ដោយនិរន្តដែល "បំពេញបានសេចក្តីត្រូវការចំពោះមុខ ដោយមិនមានការគិតគូរដល់សមត្ថភាព របស់មនុស្សនាន់ក្រោយ ក្នុងការបំពេញសេចក្តីត្រូវផ្ទាល់របស់គេ" ។ ចំពោះករណីប្រទេសកម្ពុជា បញ្ហាទាំងនេះមិនមែនជាការពិចារណាដែលគ្រាន់តែជាទ្រឹស្តីដែលគ្មានមធ្យោបាយនោះទេ ប៉ុន្តែជាសេចក្តីព្រួយបារម្ភដែលប្រាកដប្រជាបំផុត ។

៧៦- ប្រទេសកម្ពុជាមានសហគមន៍អង្គការក្រៅរដ្ឋាភិបាលដ៏រស់រវើក ។ គឺត្រូវការចាំបាច់ណាស់ក្នុងការធ្វើឱ្យគម្លាតគ្នាក្នុងការទាក់ទងរវាងរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលបានខិតចូលជិតគ្នា។ រាជរដ្ឋាភិបាលកម្ពុជា គួរតែប្រឹងប្រែងក្នុងការលើកទឹកចិត្ត ឱ្យមានការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល នៅក្នុងរាល់កិច្ចខិតខំកែទម្រង់ និងផ្តើមគំនិតក្នុងការធ្វើច្បាប់ទាំងអស់ ។ ទោះបីជាមានសញ្ញាជាវិជ្ជមានខ្លះក្នុងទិសនេះក៏ដោយ ក៏តម្រូវឱ្យមានវិធីដំណើរការជាលក្ខណៈសេរីមួយ និងត្រឹមត្រូវតាមទម្រង់ការមួយ ។ តំណាងពិសេសក៏ជំរុញដល់សហគមន៍ប្រទេសផ្តល់ជំនួយ សូមជួយគាំទ្រក្នុងការបង្កើនទំនាក់ទំនងជិតស្និទ្ធនេះ ដើម្បីធានាឱ្យការពិគ្រោះពិភាក្សាផ្តល់យោបល់គ្នាទាំងឡាយពោរពេញទៅដោយអត្ថន័យ ។

## ក- ការកែទម្រង់ផ្នែកយុត្តិធម៌

៧៧- ការកែទម្រង់រចនាសម្ព័ន្ធឡើងវិញទាំងស្រុងគឺមានសារៈសំខាន់ណាស់ចំពោះប្រព័ន្ធតុលាការ ។ ការងារនេះ ទាមទារឱ្យមានការប្រកាសប្រកាសឱ្យច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំ និងសាលាជំនុំជំរះក្តីរបស់តុលាការ និងការពិនិត្យសើរើឡើងវិញទាំងស្រុងនូវច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ចាំបាច់ជំហានដំបូងបំផុតគឺត្រូវធ្វើវិសោធនកម្មលើច្បាប់ស្តីពីគណបក្សនយោបាយ ដើម្បីដាក់ឱ្យចៅក្រម និងព្រះរាជអាជ្ញានៅដាច់ឆ្ងាយដោយឡែក មិនទទួលឥទ្ធិពលណាមួយ ។

៧៨- រាជរដ្ឋាភិបាលគួរបង្កើតនូវមូលនិធិមួយដោយឡែក សំរាប់សេវាជំនួយខាងច្បាប់សំរាប់ការពារជនអ្នកក្រីក្រ។ កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើតប្រព័ន្ធជំនួយខាងច្បាប់តាមរយៈនីតិកម្ម ត្រូវតែធ្វើឱ្យមានឡើង ដើម្បីផ្តល់លទ្ធភាពដល់ជនក្រខ្សត់ អាចដោះស្រាយរកយុត្តិធម៌តាមផ្លូវតុលាការ។

៧៩- រាជរដ្ឋាភិបាលគួរតែបង្កើនធនធានក្នុងថវិការជាតិ ដើម្បីកែប្រែប្រព័ន្ធតុលាការដែលមានភាពពិការចេញ និងផ្តល់ស្វ័យភាពដល់តុលាការ ទាំងក្នុងការផ្តល់ និងទាំងក្នុងការប្រើប្រាស់ថវិកា។

៨០- រាជរដ្ឋភិបាលត្រូវបញ្ចប់ឯកសារជាយុទ្ធសាស្រ្ត និងផែនការសកម្មភាព សំរាប់ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយចាត់ទុកជាបញ្ហាជាអាទិភាពជាបន្ទាន់បំផុតមួយ។ ដើម្បីឱ្យមានការចូលរួមនៅក្នុងកិច្ចដំណើរការធ្វើច្បាប់បានប្រកបដោយប្រសិទ្ធិភាព រដ្ឋសភា និងព្រឹទ្ធសភា គួរបានធ្វើការប្រែបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយចែងបញ្ចូលទបញ្ញត្តិសវនាការសាធារណៈ និងស្តីពីការត្រូវធ្វើការពិគ្រោះពិភាក្សាយោបល់ជាសាធារណៈ ដើម្បីធ្វើជាលក្ខខណ្ឌតម្រូវ ដែលបង្ខំឱ្យត្រូវតែធ្វើ។ ដោយយល់ឃើញអំពីសារៈសំខាន់នៃសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រមព្រហ្មទ័ណ្ឌ នាពេលខាងមុខនេះ រាជរដ្ឋាភិបាលគួរតែផ្តួចផ្តើមគំនិត បើកឱ្យមានការពិគ្រោះពិភាក្សាយោបល់ជាសាធារណៈ ឱ្យបានទូលំទូលាយ ដើម្បីផ្តល់ឱកាសឱ្យបានគ្រប់គ្រាន់ដល់សាធារណៈជន សំរាប់ធ្វើការពិនិត្យឡើងវិញ និងជួយផ្តល់យោបលលើក្រមទាំងនេះ។

៨១- រាជរដ្ឋាភិបាល គួរពិចារណាក្នុងការបង្កើតនូវសាលាឧទ្ធរណ៍ប្រចាំតាមតំបន់ ឬចល័ត។

៨២- ប្រព័ន្ធតុលាការសំរាប់អនីតិជនគួរបានបង្កើតឱ្យមានឡើង។

## ខ- ការសម្លាប់ដោយហ្វូងមនុស្ស

៨៣- រាជរដ្ឋាភិបាលគួរបង្កើតក្រុមប្រឹក្សាស៊ើបអង្កេតឯករាជមួយ ដើម្បីធ្វើការវាយតម្លៃថាហេតុអ្វីបានជាកើតមានការវាយប្រហារដោយហ្វូងមនុស្ស ហើយថាតើត្រូវធ្វើដូចដើម្បីទប់ស្កាត់ ការវាយប្រហារនេះ។

## គ- ពន្ធនាគារ

៨៤- រាជរដ្ឋាភិបាលគួរតែពិចារណា ក្នុងការដាក់បញ្ចូលការកាត់ទោស ដោយប្រើវិធីផ្សេងជំនួសការផ្តន្ទាទោសដោយដាក់ពន្ធនាគារ ចំពោះអនីតិជន និងអ្នកដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាលើកទី១។

៨៥- រាជរដ្ឋាភិបាលគួរខិតខំប្រឹងប្រែងថែមទៀត ដើម្បីធានាក្នុងការដាក់ឱ្យនៅដាច់ដោយឡែកពីគ្នានូវអ្នកទោស ទៅតាមប្រភេទផ្សេងៗគ្នា។

៨៦- រាជរដ្ឋាភិបាលគួរធានាក្នុងការអនុញ្ញាតឱ្យចូលពន្ធនាគារ និងការចូលជួបអ្នកទោសបាន ដោយសេរី ដោយមេធាវី សមាជិកក្រុមគ្រួសារ និងអង្គការក្រៅរដ្ឋាភិបាលនានា ដូចដែលធ្លាប់បានធ្វើកន្លងមក។

៨៧- រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងឡើង ចំពោះបញ្ហាឃុំខ្លួនបណ្តោះអាសន្ន រង់ចាំការវិនិច្ឆ័យទោសហួសកំណត់ពេល។

## ឃ- ការបោះឆ្នោត

៨៨- រាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែធានាក្នុងការបើកឱ្យប្រើប្រាស់ដោយស្មើភាពគ្នា នូវប្រព័ន្ធផ្សព្វផ្សាយពត៌មានរដ្ឋ និងខិតខំឱ្យយ៉ាងអស់លទ្ធភាពក្នុងការជំរុញការបើកឱ្យប្រើប្រាស់នូវប្រព័ន្ធផ្សព្វផ្សាយពត៌មានដែលមិនមែនជារបស់រដ្ឋ ជាពិសេសប្រព័ន្ធផ្សព្វផ្សាយពត៌មានអេឡិចត្រូនិក។

៨៩- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងប្រព័ន្ធតុលាការកម្ពុជា គួរតែប្រើប្រាស់ភារកិច្ចស្របច្បាប់របស់ខ្លួន ដើម្បីចាត់វិធានការឱ្យបានម៉ឺងម៉ាត់ចំពោះបុគ្គលទាំងឡាយណា ដែលត្រូវទទួលខុសត្រូវចំពោះអំពើហឹង្សា ការបំភិតបំភ័យ និងការជ្រៀតជ្រែកផ្សេងទៀត នៅក្នុងការប្រើប្រាស់ដោយសេរីនូវសិទ្ធិការបោះឆ្នោត ឬនៅក្នុងដំណើរការនៃកិច្ចដំណើរការបោះឆ្នោត ដោយត្រឹមត្រូវ។

## ង- បញ្ហាដីធ្លី និងព្រៃឈើ

៩០- រាជរដ្ឋាភិបាលគួរចាត់វិធានការធ្វើការពិនិត្យសើរើឡើងវិញ នូវកិច្ចសន្យាសម្បទានដីធ្លីទាំងអស់ និងការអនុវត្តន៍កិច្ចសន្យាទាំងនេះ និងពិនិត្យពិចារណារក្នុងការប្រើសិទ្ធិស្របច្បាប់របស់ខ្លួន ដើម្បីធ្វើការដកហូតវិញនូវកិច្ចសន្យាណា ដែលរំលោភលើបទបញ្ញត្តិនៃច្បាប់កម្ពុជា និងលក្ខខណ្ឌនៃកិច្ចសន្យា។

៩១- រាជរដ្ឋាភិបាល គួររៀបចំធ្វើនិងអនុម័តច្បាប់ ចេញនូវអនុក្រិត្យមួយដែលតម្រូវឱ្យធ្វើជាចាំបាច់ ដោយមានការពិគ្រោះពិភាក្សាយោបល់ កំណត់នីតិវិធីកាត់បន្ថយដីសម្បទានណា ដែលមានទំហំលើសពី ១0000ហិកតា និងជាក់លាក់ដែលត្រូវលើកលែងមិនកាត់បន្ថយ។ មិនត្រូវបន្តអនុញ្ញាតផ្តល់ដីសម្បទានតទៅទៀតទេ រហូតទាល់តែអនុក្រិត្យស្តីពីនីតិវិធីផ្តល់ដីសម្បទានត្រូវបានអនុម័តរួចសិន។

៩២- សហគមន៍អន្តរជាតិ គួរតែធានាថា នៅក្នុងគំរោងការនានាក្នុងការអភិវឌ្ឍន៍ដែលខ្លួនឧបត្ថម្ភគាំទ្រ ត្រូវមានតែងបញ្ចូលនូវបញ្ញត្តិស្តីពីការពិគ្រោះយោបល់ឱ្យបានត្រឹមត្រូវ និងដ៏មានខ្លឹមសារជាមួយអង្គការក្រៅរដ្ឋាភិបាល និងប្រជាពល រដ្ឋដែលមានផលប៉ះពាល់ផង។

## ច- តំបន់នៃការតាំងទីលំនៅថ្មី

៩៣- រាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន គួរចាត់វិធានការឱ្យបានគ្រប់គ្រាន់ ដើម្បីធ្វើឱ្យធូរស្រាលនូវបញ្ហាសន្តិសុខ ទឹកមិនស្អាត អនាម័យ និងសុខភាពនិងសម្ភារៈសំរាប់អប់រំផ្សេងៗ គួបផ្សំទៅនឹងបញ្ហាខ្វះដីធ្លី។ គោលនយោបាយ និងការអនុវត្តន៍ក្នុងបញ្ហាទាក់ទងនេះ ត្រូវណែនាំដោយឯកសារណែនាំសំរាប់ការតាំងទីលំនៅថ្មី ដែលធ្វើកាលពីខែសីហា ឆ្នាំ ២00១។

## ឆ- ការជួញដូរមនុស្ស

៩៤- រាជរដ្ឋាភិបាលគួរបន្តប្រយុទ្ធនឹងការជួញដូរមនុស្ស ដោយផ្តល់ការអប់រំឱ្យបានត្រឹមត្រូវ ដល់មន្ត្រីពង្រឹងអនុវត្តច្បាប់ និងដោយការពង្រឹងការអនុវត្តន៍ច្បាប់។

៩៥- តុលាការត្រូវផ្តល់ការដោះស្រាយសំណងជួសជុលការខូចខាត ដល់មនុស្សដែលត្រូវចាប់ពង្រត់ ដែលត្រូវចាត់ទុកថាជាជនរងគ្រោះ។ រាជរដ្ឋាភិបាលគួរតែធ្វើការកាត់ទោសរាល់ជនល្មើសទាំងអស់ រហូតដល់ថ្នាក់ខ្ពស់បំផុតនៃបណ្តាញដែលរកស៊ីជួញដូរមនុស្ស។

## ជ- អ្នកស្វែងរកសិទ្ធិជ្រកកោន

៩៦- រាជរដ្ឋាភិបាលត្រូវបានជំរុញឱ្យប្រតិបត្តិឱ្យបានពេញលេញ នូវកាតព្វកិច្ចរបស់ខ្លួន ក្នុងការធ្វើរបាយការណ៍ស្របតាមអនុសញ្ញា ឆ្នាំ១៩៥១ ស្តីពីឋានៈរបស់ជនភៀសខ្លួន ដោយយកចិត្តទុកដាក់ជាពិសេស ទៅលើគោលការណ៍ស្នូលស្តីពីការមិនរុញច្រានឱ្យត្រឡប់ទៅវិញ។

៩៧- រាជរដ្ឋាភិបាលត្រូវធានាថា នឹងមិនមានសកម្មភាពបំភិតបំភ័យកើតឡើងបន្តទៅទៀត ចំពោះជនទាំងឡាយដែលបានជួយឧបត្ថម្ភ ដោយត្រឹមត្រូវតាមច្បាប់អ្នកដែលស្វែងរកសិទ្ធិជ្រកកោន។

## ឈ- កាតព្វកិច្ចធ្វើរបាយការណ៍

៩៨- រាជរដ្ឋាភិបាលត្រូវបំពេញកាតព្វកិច្ច ក្នុងការធ្វើរបាយការណ៍របស់ខ្លួនឱ្យបានទាន់ តាមពេលវេលាកំណត់ និងដោយ មានលក្ខណៈជាដុំកំភួន។ អនុសាសន៍លើកឡើងដោយអង្គការត្រួតពិនិត្យសន្ធិសញ្ញាគួរបានយកមកពិចារណាដោយប្រុងប្រយ័ត្ន ដើម្បីពង្រឹងការអនុវត្តន៍នូវសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។